00969105

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*លេខ៖ D121/4/1/4*

***តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (**អបជ០៥**)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម នេយ ថុល**
**ចៅក្រម** Chang-Ho CHUNG
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: **ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 01 / 2014
ម៉ោង (Time/Heure) : 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

**សំណៅសាធារណៈ: កោសលុប**

**ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេច បដិសេធលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត**

| **សហព្រះរាជអាជ្ញា** | **មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី** | |
|---|---|---|
| ជា លាង | ជេត វណ្ណលី | Christine MARTINEAU |
| Nicholas KUMJIAN | ហុង គឹមសួន | Barnabe NEKUI |
| | គឹម ម៉េងឃី | Lyma NGUYEN |
| | ឡោ ជុនធី | Philippine SUTZ |
| | សំ សុគង់ | Emmanuel JACOMY |

ទី ស្រ៊ុនណា | Madhev MOHAN
វ៉ែន ពៅ | គង់ ផល្លៈ

Annie DELAHAIE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
François GAUTRY
Martine JACQUIN

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើរបស់ក្រុមការពារក្តីសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត” ដែលសហមេធាវីការពារក្តី [redacted] បានដាក់កាលពីថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣ (“បណ្តឹងឧទ្ធរណ៍”)[1]។

## I. **សេចក្តីផ្តើម**

1. បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបដិសេធសំណើសុំចំនួនពីររបស់ [redacted] ស្នើសុំពិនិត្យមើលសំណុំរឿងនៅក្នុងសំណុំរឿង០០៤ តាមរយៈមេធាវីរបស់គាត់ និងស្នើសុំការអនុញ្ញាតឱ្យចូលរួមនៅក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ។ ការបដិសេធសំណើសុំនេះផ្អែកលើមូលដ្ឋានថា គាត់មិនទាន់ត្រូវបានចោទប្រកាន់នោះទេ។

### ក. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីនៅពេលនោះ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ”) ជូនសហចៅក្រមស៊ើបអង្កេត ដែលតាមរយៈនេះ បានបើក និងចាប់ផ្តើមជាផ្លូវការនូវកិច្ចស៊ើបសួរតាមផ្លូវតុលាការទៅលើ *ក្នុងចំណោមនោះ* បទឧក្រិដ្ឋនានាដែល [redacted] ត្រូវបានចោទប្រកាន់ថាត្រូវទទួលខុសត្រូវ[2]។

3. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ និងថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ អង្គភាពគាំពារការការពារក្តីបានស្នើសុំឱ្យជនសង្ស័យក្នុងសំណុំរឿង ០០៤ ពិនិត្យមើលឯកសារសំណុំរឿង និងស្នើសុំឱ្យផ្តល់សិទ្ធិផ្នែកនីតិវិធីផ្សេងទៀត រួមទាំងសិទ្ធិចូលរួមនៅក្នុងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការដូចមាន

[1] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើរបស់ក្រុមការពារក្តីសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត ដែលដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣ និងដាក់ជាភាសាខ្មែរនៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារD121/4/1/1 (“បណ្តឹងឧទ្ធរណ៍”)។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សេចក្តីជូនដំណឹងនៃការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ D1/1។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

ចែងនៅក្នុងវិធាន៥៥(៨) និង ៥៥(១០) នៃវិធានផ្ទៃក្នុង[3]។ សំណើសុំស្រដៀងគ្នានេះ ត្រូវបានស្នើសុំជាថ្មីម្តងទៀត ដោយមេធាវីកម្ពុជាមួយរូបដែលត្រូវបានចាត់តាំងដោយអង្គភាពគាំពារការការពារក្តីឱ្យតំណាងឱ្យផលប្រយោជន៍របស់ជនសង្ស័យដែលមិនបង្ហាញឈ្មោះ នៅក្នុងសំណុំរឿង ០០៤ កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ និងថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១[4]។ សំណើសុំទាំងនេះត្រូវបានសហចៅក្រមស៊ើបអង្កេតទាំងពីរដែលកាន់ដំណែងនៅពេលនោះ (ចៅក្រម យូ ប៊ុនឡេង និងចៅក្រម BLUNK) បដិសេធចោលទាំងអស់ ដោយផ្អែកលើមូលដ្ឋានថា ជនសង្ស័យ មិនដែលទាន់ត្រូវបានចោទប្រកាន់តាមនីតិវិធីដែលមានចែងនៅក្នុងវិធាន ៥៧ នៃវិធានផ្ទៃក្នុង មិនមែន "ជាភាគីនៃកិច្ចដំណើរការនីតិវិធី" នោះទេ ហេតុដូច្នេះមិនមានសិទ្ធិពិនិត្យមើលសំណុំរឿងទេ។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញបន្ថែមទៀតថា ជនសង្ស័យមិនទាន់ត្រូវបាន "ប៉ះពាល់ធ្ងន់ធ្ងរ" ដោយការស៊ើបអង្កេតទាំងនោះទេ[5]។

4. នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងដែលកាន់តំណែងនៅពេលនោះ (ចៅក្រម KASPER-ANSERMET) បានជូនដំណឹងដល់ [redacted] ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ថា "គាត់មានឈ្មោះជាជនសង្ស័យនៅក្នុងកិច្ចស៊ើបសួររបស់តុលាការដែលកំពុងដំណើរការ" និងថា "យោងតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក [វិធាន ២១(១) (ឃ)] សិទ្ធិ និងការធានាតាមនីតិវិធី ដែលបានភ្ជាប់ទៅនឹងឋានៈជាជនសង្ស័យ រួមមាន សិទ្ធិទទួលបានការ

---

[3] លិខិតរបស់ប្រធានអង្គភាពគាំពារការការពារក្តីផ្ញើជូនសហចៅក្រមស៊ើបអង្កេត ដែលមានចំណងជើង "លិខិតរបស់អង្គភាពគាំពារការការពារក្តីស្តីពីសិទ្ធិការការពារក្តីនៅក្នុងសំណុំរឿង០០៣ និង០០៤" ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D4.1.29។ លិខិតរំឭករបស់អង្គភាពគាំពារការការពារក្តី ស្តីពីសិទ្ធិការការពារក្តីនៅក្នុងសំណុំរឿង០០៣ និង០០៤ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ A1/1។

[4] សំណើពិនិត្យសំណុំរឿង ០០៣ និង ០០៤ ដែលដាក់ដោយ គង់ សំអុន នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ D4។ សំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំពិនិត្យមើលសំណុំរឿងលេខ ០០៣ និងលេខ ០០៤ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D4/2។

[5] លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនប្រធានអង្គភាពគាំពារការការពារក្តី ដែលមានចំណងជើង "ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿង០០៣ និង០០៤" ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D4.1.31។ ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ០០៣ និងលេខ០០៤ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D4/1។ ដីកាសម្រេចស្តីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D4/2/1។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER / CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

ការពារពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន និងសិទ្ធិក្នុងការពិនិត្យសំណុំរឿងផងដែរ" ("សេចក្តីជូនដំណឹងចុះថ្ងៃទី ២៩ ខែ កុម្ភៈ")[6]។

5. នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ [redacted] បានតែងតាំងមេធាវីឱ្យតំណាងរូបគាត់[7] ដែលត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ដែលកាន់តំណែងនៅពេលនោះ ថាជាសហមេធាវីរបស់ [redacted] នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ អនុលោមតាមវិធាន ២២ (២)(ក) នៃវិធានផ្ទៃក្នុង[8]។

6. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ [redacted] បានដាក់សំណើជាបន្ទាន់ស្នើសុំដីកាបង្គាប់ឱ្យអនុញ្ញាតពិនិត្យមើលសំណុំរឿង ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់ឱ្យការិយាល័យរដ្ឋបាលអនុញ្ញាតឱ្យគាត់ពិនិត្យមើលសំណុំរឿង នៅក្នុងសំណុំរឿង០០៤ ("សំណើសុំពិនិត្យមើលសំណុំរឿង")[9]។ សំណើសុំនេះត្រូវបានស្នើសុំសាជាថ្មី នៅក្នុងលិខិតមួយដែលផ្ញើជូនទៅសហចៅក្រម

---

[6] ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ និងត្រូវបានជូនដំណឹងនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D110។ *សូមមើលផងដែរ* លិខិតផ្ញើជូនអង្គភាពគាំពារការការពារក្តីស្តីពីការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D111 កថាខណ្ឌ៤។

[7] ទម្រង់បែបបទលេខ ៧៖ សំណើសុំចាត់តាំងសហមេធាវី ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D111/2.1 (ខណៈពេលដែល [redacted] សុំចាត់តាំង មុំ លុជ្ជ និង Richard ROGERS ជាមេធាវីរបស់គាត់)។

[8] ដីកាសម្រេចលើលិខិតទទួលស្គាល់មេធាវី សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ D111/5 (ទទួលស្គាល់ មុំ លុជ្ជ និង Richard ROGERS ជាសហមេធាវីការពារក្តី [redacted])។ ក្រោយមក ដីកាសម្រេចនេះត្រូវបានលុបចោលដោយសហចៅក្រមអន្តរជាតិ ត្រង់ចំណុចដែលពាក់ព័ន្ធនឹងការទទួលស្គាល់ Richard ROGERS។ *សូមមើល* ដីកាសម្រេចលើញត្តិ និងសារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D122/6 ("ដីកាសម្រេចស្តីពីសិទ្ធិមានមេធាវី")។ កាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២ [redacted] បានចាត់តាំងបន្ថែម Göran SLUITER ដើម្បីតំណាងឱ្យគាត់ ដែលមេធាវីត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិទទួលស្គាល់នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣។ *សូមមើល* ទម្រង់៧៖ ទម្រង់៧៖ សំណើសុំចាត់តាំងសហមេធាវី ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២ ឯកសារ D111/8 *និង* ដីកាសម្រេចស្តីពីសិទ្ធិមានមេធាវី កថាខណ្ឌ១០៩។

[9] សំណើជាបន្ទាន់សុំដីកាបង្គាប់ឱ្យពិនិត្យមើលសំណុំរឿង ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D121/2/1.1.1 ("សំណើសុំពិនិត្យមើលសំណុំរឿង")។

ស៊ើបអង្កេតកាលពីថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២[10] និងដាក់ជាថ្មីម្តងទៀត នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣[11] បន្ទាប់ពីមានសេចក្តីសម្រេចមួយដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ចៅក្រម HARMON) កាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ដែលចៅក្រមរូបនេះ បាន អនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពិនិត្យមើលសំណុំរឿង នៅក្នុងសំណុំរឿង 00៤[12]។

7. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ [redacted] បានដាក់ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើបន្ទាន់សុំចេញដីកាសម្រេចឱ្យបើកមើលសំណុំរឿង"[13] ហើយក្រោយមកនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ បណ្តឹងឧទ្ធរណ៍នេះត្រូវបានដកចេញវិញ[14] បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់ព័ត៌មានអំពីការពិចារណាលើសំណើសុំពិនិត្យមើលសំណុំរឿង[15]។

---

[10] លិខិតរបស់ មុំ លុជ្ស, Richard ROGERS និង Göran SLUITER ផ្ញើជូនសហចៅក្រមស៊ើបអង្កេតដែលមានចំណងជើង "សិទ្ធិ [redacted] ក្នុងការទទួលបានព័ត៌មាន ស្តីពីប្រភេទ និងមូលហេតុនៃបទចោទមកលើរូបគាត់ និងសិទ្ធិទទួលបានសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់ត្រៀមរៀបចំការពារក្តីរបស់ខ្លួន" ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D121/1។

[11] លិខិតរបស់ មុំ លុជ្ស និង Göran SLUITER ផ្ញើជូនសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា "ពាក់ព័ន្ធនឹងការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតរបស់ [redacted] ពិនិត្យមើលសំណុំរឿង" ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D122/7។

[12] សេចក្តីសម្រេចទទួលស្គាល់មេធាវីទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង00៤ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ D126។

[13] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើបន្ទាន់សុំចេញដីកាសម្រេចឱ្យបើកមើលសំណុំរឿង ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D121/2/1។

[14] ការជូនដំណឹងពីការដកបណ្តឹងឧទ្ធរណ៍ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ D121/2/2។ សេចក្តីសម្រេចស្តីពីការជូនដំណឹងស្តីពីការដកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតនូវសំណើសុំចេញដីកាអនុញ្ញាតឱ្យពិនិត្យសំណុំរឿង ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ D121/2/3។

[15] កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបញ្ជូនបន្តបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D121/2។



E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

8. កាលពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ [redacted] បានស្នើសុំសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឱ្យគាត់ចូលរួមនៅក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការនៅក្នុងសំណុំរឿង ០០៤ សំខាន់គឺដើម្បីស្នើសុំតាំងសំណួរសួរទៅកាន់សាក្សី ("សំណើសុំការចូលរួមនៅក្នុងការស៊ើបអង្កេត")[16]។

9. កាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ចៅក្រម HARMON) បានបដិសេធចោលសំណើសុំពិនិត្យមើលសំណុំរឿង និងបដិសេធចោលការចូលរួមនៅក្នុងការស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋានថា [redacted] ដែលមិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការ មិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីទេ ហេតុដូច្នេះ គាត់មិនមានសិទ្ធិចូលរួមក្នុងការស៊ើបអង្កេត ឬមិនមានសិទ្ធិពិនិត្យមើលសំណុំរឿងទេ ("សេចក្តីសម្រេចដែលរងការជំទាស់")[17]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានពិចារណាឡើងវិញ លើផ្នែកផ្សេងៗនៃការជូនដំណឹងចុះថ្ងៃទី ២៩ ខែ កុម្ភៈ (ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់) ដែលផ្តល់ការអនុញ្ញាតឱ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង និងលុបចោលការជូនដំណឹងទាំងនោះ[18]។

10. កាលពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៣ [redacted] បានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចដែលរងការជំទាស់[19] ហើយនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣ គាត់បានដាក់បណ្តឹងឧទ្ធរណ៍។ នៅក្នុងបណ្តឹងឧទ្ធរណ៍ [redacted] បានស្នើសុំអង្គបុរេជំនុំជម្រះឱ្យបើកសវនាការជាសាធារណៈមួយ ដើម្បីស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់ មុនពេលសម្រេចលើបណ្តឹងឧទ្ធរណ៍[20]។

---

[16] លិខិតរបស់ មុំ លុជ្ស និង Göran SLUITER ផ្ញើជូនទៅសហចៅក្រមស៊ើបអង្កេត ដែលមានចំណងជើង "ការចូលរួមរបស់សហមេធាវីការពារក្តីក្នុងដំណើរការស៊ើបអង្កេតសំណុំរឿង០០៤" ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D121/3 ("សំណើសុំការចូលរួមនៅក្នុងការស៊ើបអង្កេត")។

[17] សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ D121/4 ("សេចក្តីសម្រេចដែលរងការជំទាស់")។

[18] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៤៩។

[19] ការជូនដំណឹងរបស់ [redacted] ក្នុងការប្តឹងឧទ្ធរណ៍លើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ក្រុមការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D121/4/1។

[20] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

00969112



11. សហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់ចម្លើយតប ឬសារណាទៅតាមកាលកំណត់នៃការដាក់ឯកសារ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនោះទេ។

## ខ. បណ្តឹងឧទ្ធរណ៍

12. [redacted] បានលើកឡើងថា ពាក់ព័ន្ធនឹងការបដិសេធចោលសំណើសុំចូលរួមនៅក្នុងការស៊ើបអង្កេត បណ្តឹងឧទ្ធរណ៍អាចទទួលយកបានផ្អែកតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបដិសេធចោលសំណើសុំបំពេញកិច្ចស៊ើបសួរ[21]។ [redacted] លើកឡើងបន្ថែមថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានទាំងស្រុងផ្អែកតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយសារតែបណ្តឹងឧទ្ធរណ៍ "មានទាក់ទងនឹងសិទ្ធិជាមូលដ្ឋាន ដែលជាបញ្ហាចម្បងនៃភាពត្រឹមត្រូវនៃនីតិវិធី ក៏ដូចជាការពិចារណាទៅលើគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី"[22]។

13. ចំពោះផ្អែកតាមអង្គសេចក្តី [redacted] លើកទឡ្ហីករណ៍ថា i) ដីកាសម្រេចដែលរងការជំទាស់ "ត្រូវបានអះអាងបញ្ជាក់ផ្អែកលើការបកស្រាយដោយខុសឆ្គងអំពីអំណាចតុលាការ ក្នុងការពិចារណាឡើងវិញ"។ ii) "[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] មានកំហុសឆ្គងដោយមិនបានបកស្រាយ "បទចោទព្រហ្មទណ្ឌ" ថាជាទស្សនៈទានស្វ័យភាព និងឱ្យស្របតាមគោលដៅ និងគោលបំណងរបស់បទចោទនោះដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌"។ iii) "[គាត់] ត្រូវបានចោទប្រកាន់ពី "បទឧក្រិដ្ឋ" ក្រោមការវាយតម្លៃដោយឡែកពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ECtHR ដូចធ្លាប់បានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Siegfried Blunk ក្នុងសំណុំរឿង០០៤"។ iv) "សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសនៅក្នុងការបដិសេធផលប៉ះពាល់ពីការចុះផ្សាយពីបណ្តាញសារព័ត៌មាននៅក្នុងសំណុំរឿងនេះ និងមិនអើពើចំពោះផលប៉ះពាល់របស់ករណីនេះទាក់ទងនឹងសុខភាពទ្រុឌទ្រោមរបស់ [គាត់]"។ v) "ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិរំលោភគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី" និង vi) "[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] មានកំហុសនៅក្នុងការអនុញ្ញាតឱ្យមើលសំណុំរឿងដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងធ្វើឱ្យកាន់តែធ្ងន់ធ្ងរនូវវិសមភាពនីតិវិធីប្រឆាំងនឹង

[21] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១។

[22] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២-១៣។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

[គាត់]"[23]។ ហេតុដូច្នេះ [redacted] ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលដីកាសម្រេចដែលរងការជំទាស់ និង "បញ្ជាឱ្យមេធាវីការពារក្តីរបស់[គាត់]បានមើលសំណុំរឿង"[24]។

### គ. អំណះអំណាងផ្ទាល់មាត់

14. វិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុង ចែងថា "បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ [...] ដោយផ្អែកតែលើមូលដ្ឋាន នៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។ ដោយបានពិចារណាលើសារណាជាលាយលក្ខណ៍អក្សរគ្រប់គ្រាន់ ដែលបានដាក់ក្នុងនាម [redacted] និងមិនមានការដាក់ការឆ្លើយតបណាមួយពីសហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីនោះ អង្គបុរេជំនុំជម្រះពិចារណាឃើញថាពុំមានភាពចាំបាច់ទេ ក្នុងការស្តាប់អំណះអំណាងផ្ទាល់មាត់ក្នុងករណីនេះ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះផ្តល់ការសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍នេះដូចខាងក្រោម។

## II. ការសម្តែងមតិយោបល់ និងសេចក្តីសន្និដ្ឋាន

15. ទោះបីមានការខិតខំប្រឹងប្រែងយ៉ាងណាក្តី អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ដែលចាំបាច់ដើម្បីអាចចេញសេចក្តីសម្រេចមួយលើបញ្ហានានានៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។ ដោយហេតុថា វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវមានសំអាងហេតុ ហេតុដូច្នេះទើបមតិយោបល់របស់ចៅក្រមអង្គជំនុំជម្រះត្រូវបានដាក់ភ្ជាប់នឹងសេចក្តីពិចារណាទាំងនេះ។

16. ដោយសារថា អង្គបុរេជំនុំជម្រះមិនបានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ វិធាន៧៧(១៣) នៃវិធានផ្ទៃក្នុង កំណត់ថា សេចក្តីសម្រេចដែលរងការជំទាស់ ត្រូវបានតម្កល់ទុកជាបានការ។

[23] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥។

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨១។

## III. ការសម្រេចសេចក្ដី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសូម÷**

ប្រកាសជាឯកច្ឆន្ទថា អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ក្នុងការចេញសេចក្ដីសម្រេចលើសំណើសុំពិនិត្យសំណុំរឿងនេះបានឡើយ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ភាគីមិនមានលទ្ធភាពប្ដឹងតវ៉ាទេ។

**ភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន** **Rowan DOWNING** **ន័យ ចុល** **Chang-ho CHUNG** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គីម សាន ចៅក្រម ន័យ ចុល និង ចៅក្រម ហួត វុទ្ធី សូមដាក់ភ្ជាប់មតិយោបល់របស់ខ្លួន។

ចៅក្រម Rowan DOWNING និង ចៅក្រម Chang-ho CHUNG សូមដាក់ភ្ជាប់មតិយោបល់របស់ខ្លួន។

## មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន៉័យ ថុល និងចៅក្រម ហួត វុទ្ធី

### ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

1. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើរបស់ក្រុមការពារក្តី សុំពិនិត្យលើឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៧៣ នៃវិធានផ្ទៃក្នុង ដែលឋិតក្នុងយុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ។ វិធាន៧៣ (ក) នៃវិធានផ្ទៃក្នុង ចែងថា៖ បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេច និងកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដូចមានចែងនៅក្នុងវិធាន ៧៤។

2. វិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ចែងថា *ជនត្រូវចោទ ឬ ជនជាប់ចោទ* អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែល "បដិសេធពាក្យសុំឲ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។"

3. យើងនឹងពិនិត្យមើលថាតើ [redacted] មានឋានៈជា *ជនត្រូវចោទ* ឬ *ជនជាប់ចោទ* ដែរឬទេ?

4. ក្រុមការពារក្តីជនសង្ស័យ [redacted] បានបញ្ជាក់ថា "វិធានផ្ទៃក្នុងបានចែងក្នុងវិធាន ២១ ស្តីពីគោលការណ៍ណែនាំអធិកភាពក្នុងការបកស្រាយសិទ្ធិនានា នៅចំពោះមុខ អ.វ.ត.ក ថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជា ធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ជនសង្ស័យ"[1]។

5. ក្រុមការពារក្តីជនសង្ស័យ [redacted] ក៏បានយោងផងដែរលើវិធាននានានៃវិធានផ្ទៃក្នុង ស្តីពីសិទ្ធិក្នុងការមើលសំណុំរឿង ដូចខាងក្រោម[2]៖

   - វិធាន៥៥(៦) "ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុ និងរបាយការណ៍នៃការស៊ើបសួរ។ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិគ្រប់ពេលវេលា

---

[1] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៤។

[2] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៥។

E.C.C.C • C.E.T.C PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងពេលម៉ោងធ្វើការ និងគោរពទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ។"

- វិធាន៨៦ ចែងថា "នៅគ្រប់ពេលវេលា សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិពិនិត្យមើល និង ថតចម្លងសំណុំរឿង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលម៉ោងធ្វើការ និងត្រូវគោរពទៅតាមល័ក្ខខ័ណ្ឌតម្រូវសម្រាប់ដំណើរការល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។"

- វិធាន៥៥(១១)៖ "សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីពាក់ព័ន្ធមានសិទ្ធិសុំមើលសំណុំរឿងច្បាប់ដើម ប៉ុន្តែត្រូវគោរពទៅតាមពេលវេលាកំណត់ ដើម្បីធានាដល់និរន្តរភាពនៃកិច្ចដំណើរការនីតិវិធី។"

- វិធាន២២(៣)៖ "[...]មេធាវីនេះអាចទទួលបានច្បាប់ចម្លងនៃសំណុំរឿង ឬ កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី និងយកឯកសារនេះ រួមជាមួយឯកសារដែលពាក់ព័ន្ធដទៃទៀត ដើម្បីពិភាក្សាជាមួយកូនក្តីរបស់ខ្លួន។"

6. វិធានផ្ទៃក្នុងដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងខាងលើ មានប្រើពាក្យ *"ជនសង្ស័យ"* និង *"ភាគី"*។ អនុលោមតាមសន្ទានុក្រមនៃវិធានផ្ទៃក្នុង ពាក្យ *"ជនសង្ស័យ" (Suspect)* "សំដៅទៅលើបុគ្គលដែលសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ចាត់ទុកថាអាចធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមិនទាន់ត្រូវចោទប្រកាន់នៅឡើយ"។ រីឯពាក្យ *"ភាគី" (Party)* "សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី"។

7. តាមការកត់សម្គាល់ យើងសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតពុំទាន់បានធ្វើការចោទប្រកាន់ ឬដាក់ឱ្យស្ថិតក្រោមការពិនិត្យជនណាម្នាក់ជាផ្លូវការនៅឡើយ នៅក្នុងសំណុំរឿង ០០៤។ ក្រុមការពារក្តីជនសង្ស័យបានធ្វើការផ្លាស់ប្តូរឋានៈដោយខ្លួនឯងពី "ជនសង្ស័យ" ទៅជា "ជនត្រូវចោទ" ខណៈដែលសហចៅក្រមស៊ើបអង្កេតមិនទាន់ធ្វើការផ្លាស់ប្តូរឋានៈនេះជាផ្លូវការនៅឡើយ។ នៅក្នុងសំណើរបន្ទាន់របស់ខ្លួន ក្រុមការពារក្តីជនសង្ស័យបានដកស្រង់សទ្ទានុក្រមនៃវិធានផ្ទៃក្នុង "ជនត្រូវចោទ" សំដៅលើ "បុគ្គលណាម្នាក់ដែលត្រូវចោទប្រកាន់ចំពោះក្តីរឿងណាមួយ ក្នុងចន្លោះពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់"។ យើងឯកភាពលើការលើកឡើងរបស់



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00969117



សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា និយមន័យនេះសំដៅលើ "ជនត្រូវចោទ" គឺមិនមែនសម្រាប់ជនសង្ស័យដែលមិនទាន់ត្រូវចោទប្រកាន់ ហើយនិយមន័យនេះ គ្រាន់តែផ្តល់ក្របខ័ណ្ឌពេលវេលាដែលបុគ្គលម្នាក់ អាចក្លាយជាជនត្រូវចោទតែប៉ុណ្ណោះ[3]។ ម្យ៉ាងទៀត បើតាមភាសាបារាំង "ជនត្រូវចោទ" ***(Personne mise en examen)*** មានន័យថា "ជនដែលត្រូវបានដាក់ឱ្យស្ថិត ក្រោមការពិនិត្យ" ហើយនៅពេលនេះ សហចៅក្រមស៊ើបអង្កេតពុំទាន់បានដាក់ [redacted] ឱ្យស្ថិតក្រោមការពិនិត្យ ដូចមានចែងក្នុងវិធាន ៥៥ នៃវិធានផ្ទៃក្នុង និងមាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទេ។

8. ហេតុដូច្នេះ ជនសង្ស័យម្នាក់មិនមែនជាភាគីមួយនៅក្នុងដំណើរការនីតិវិធីឡើយ ហើយជនសង្ស័យមិនមែនជាជនត្រូវចោទ ដូច្នេះទើបមិនមែនជាភាគីណាមួយឡើយ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។

9. ផ្អែកតាមមាត្រា ១២៤ ស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អនុម័តថ្ងៃទី៧ ខែ មិថុនា ឆ្នាំ២០០៧ ចែងថា៖

> "ការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមមាត្រា៤៤នៃក្រមនេះ។ ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលណាម្នាក់ ឬច្រើននាក់ ដោយមានការចង្អុលបង្ហាញប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន ដោយអនុលោមតាមវាក្យខ័ណ្ឌទី២ នៃមាត្រា៤៤នៃក្រមនេះ។ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។ កាលបើចៅក្រមស៊ើបសួរទទួលពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវិធីដូចមានចែងនៅមាត្រា១៣៩ និងមាត្រា ១៤០ នៃក្រមនេះ។ [...]។"

10. មាត្រា១២៦ ស្តីពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា៖

> "ចៅក្រមស៊ើបសួរ ***ត្រូវតែ***ដាក់ឱ្យស្ថិតក្រោមការពិនិត្យ នូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវ

[3] សំណុំរឿង ០០៤ ឯកសារលេខ D121/4 សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំ រឿង និងចូលរួមការស៊ើបអង្កេត ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌទី ៤៣។

បុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ [...]។

11. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី បង្កើតបានជាសំណុំរឿងលេខ ០០៤/២០-១១-២០០៨ អវតក/កសចស ដែលត្រូវបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតសម្រាប់បើកការស៊ើបសួរ ក៏ប៉ុន្តែសំណុំរឿងនេះមិនត្រូវបានឯកភាពពីសហព្រះរាជអាជ្ញាជាតិទេ[4]។

12. នៅពេលទទួលបានករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការដាក់ស្នើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី អង្គបុរេជំនុំជម្រះ "ប្រកាសថា មិនទទួលបាននូវសម្លេងគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ដើម្បីធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នានោះទេ"[5]។ ហេតុដូច្នេះ អនុលោមតាមវិធាន៧៤(១) នៃវិធានផ្ទៃក្នុង កិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវតែយកទៅអនុវត្ត។ នៅក្នុងករណីនេះ មានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីបើកកិច្ចស៊ើបសួរ ស្របតាមវិធាន៥៣(១) នៃវិធានផ្ទៃក្នុង។ ដូចនេះ បញ្ហាយុត្តាធិការបុគ្គលនៅ អ.វ.ត.ក ពុំទាន់ត្រូវបានដោះស្រាយនៅឡើយ ដែលផ្ទុយពីសំណុំរឿង ០០១ និង សំណុំរឿង ០០២។

13. ចាប់តាំងពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបីមក សហចៅក្រមស៊ើបអង្កេតពុំទាន់សម្រេចដាក់ដាក់បុគ្គលណាម្នាក់ឱ្យស្ថិតក្រោមការពិនិត្យទេ ដូច្នេះ [redacted] និងបុគ្គលផ្សេងទៀត ដែលជា *ជនសង្ស័យមិនទាន់មានឋានៈជាជនត្រូវចោទ ឬជនជាប់ចោទ* ទេ។

14. ការសម្រេចធ្វើការចោទប្រកាន់ គឺជាបុព្វសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។ អនុលោមតាម វិធាន ៥៥(៤) នៃផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតមានអំណាចឆន្ទានុសិទ្ធិចោទជនសង្ស័យណាម្នាក់ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬជនផ្សេងទៀត ប្រសិនបើមាន *"តម្រុយច្បាស់លាស់ និងស៊ី*

---

[4] ករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ឯកសារលេខ ១។

[5] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

*សង្ស័យ*"។ បទដ្ឋាននេះ ត្រូវបានអនុវត្តស៊ីសង្វាក់គ្នា នៅក្នុងករណីផ្សេងទៀត ដែលត្រូវបានស៊ើបអង្កេតដោយ ក.ស.ច.ស និងត្រូវបានលើកឡើងផងដែរ នៅក្នុងសេចក្ដីសម្រេចមុនៗ នៅក្នុងសំណុំរឿង ០០៤[6]។

15. សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា "សិទ្ធិការពារក្ដីអាចអនុវត្តបានយ៉ាងពេញលេញ (ហើយគោលការណ៍សមភាពនៃមធ្យោបាយតទល់រឿងក្ដីត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួន នៅពេលដែលជនណាម្នាក់ត្រូវបានចោទប្រកាន់ ហើយក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី ប៉ុន្តែដរាបណា ជនណាម្នាក់មិនត្រូវបានចោទប្រកាន់ជាផ្លូវការ សិទ្ធិរបស់ជននោះនៅមានកំរិតនៅឡើយ។ នេះគឺជាករណីដែលអនុវត្តនៅគ្រប់ប្រព័ន្ធនីតិវិធីទាំងអស់"[7]។ យើងយល់ស្របលើការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតលើបញ្ហានេះ។

16. ផ្អែកតាមការលើកឡើងខាងលើ ដោយសារ[គាត់] [redacted] មានឋានៈជាជនសង្ស័យនៅឡើយ គាត់ពុំមានសិទ្ធិដាក់បណ្ដឹងឧទ្ធរណ៍ ចំពោះមុខអង្គបុរេជំនុំជម្រះទេ អនុលោមតាមវិធាន៧៤(៣)(ខ) នៃ វិធានផ្ទៃក្នុង។ ហេតុដូចនេះ បណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

17. យើងប្រកាសបដិសេធមិនទទួលយកបណ្ដឹងឧទ្ធរណ៍នេះ។

**ភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤**

**ប្រាក់ គីមសាន** **ន័យ ថុល** **ហួត វុទ្ធី**

[6] សំណុំរឿង ០០២ ឯកសារលេខ D198/1 ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺអំពីបទចោទ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

[7] សំណុំរឿង ០០៤ ឯកសារលេខ D4.1.31 ចម្លើយតបរបស់ ស.ច.ស ស្ដីពីសិទ្ធិការពារក្ដី នៅក្នុងសំណុំរឿងលេខ ០០៣ និង០០៤ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០។

## មតិយោបល់របស់ចៅក្រម ROWAN DOWNING និង CHANG-HO CHUNG

### I. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

1. [redacted] លើកឡើងថា ត្រឹមចំណុចដែលខ្លួនតវ៉ានឹងសេចក្តីសម្រេចបដិសេធចោលសំណើសុំរបស់ខ្លួនក្នុងការចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានផ្អែកតាមវិធាន ៧៤(៣)(ខ)[1]។ គាត់លើកឡើងបន្ថែមទៀតថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានទាំងមូល ផ្អែកតាមវិធាន២១ នៃវិធានផ្ទៃក្នុង ដោយសារតែ "ទាក់ទងនឹងសិទ្ធិជាមូលដ្ឋាន ដែលជាបញ្ហាចម្បងនៃភាពត្រឹមត្រូវនៃនីតិវិធី ក៏ដូចជាការពិចារណាទៅលើគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី"[2]។ តាមការយល់ឃើញរបស់ [redacted] "ការពិតដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធដោយខុសឆ្គងលើសិទ្ធិរបស់ [គាត់] ដែលគួរតែអាចអនុវត្តបានចំពោះជនសង្ស័យ និងជនត្រូវចោទ មិនគួរមានការប៉ះពាល់ដល់ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះទេ"[3]។

2. ចំណុចសំខាន់នៃបណ្តឹងឧទ្ធរណ៍ លើកឡើងអំពីបញ្ហាថាតើ [redacted] ក្នុងនាមជាជនសង្ស័យមួយរូបដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មានសិទ្ធិចូលរួមនៅក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះដែរឬយ៉ាងណា តាមរយៈការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ។ ដីកាសម្រេចដែលរងការជំទាស់មិនអនុញ្ញាតឱ្យ [redacted] ចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ដរាបណាគាត់មិនត្រូវបានចោទប្រកាន់ជាផ្លូវការ ដោយមិនត្រឹមតែបដិសេធចោលសំណើសុំចូលរួមនៅក្នុងការស៊ើបអង្កេតនោះទេ ប៉ុន្តែថែមទាំងបដិសេធចោលសំណើរបស់គាត់ស្នើសុំពិនិត្យមើលសំណុំរឿងផងដែរ។ ដោយសារតែមិនបានអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង លទ្ធភាពរបស់ [redacted] ក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរពិតជាត្រូវបានកំហិត ឬមិនមានលទ្ធភាពតែម្តង។ បណ្តឹងឧទ្ធរណ៍អះអាងថា ដីកាសម្រេចដែលរងការជំទាស់បានរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ [redacted] ដូចមានចែងនៅក្នុងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

---

[1] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១។

[2] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។

[3] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

("ICCPR") និងវិធាន២១ នៃវិធានផ្ទៃក្នុង ជាពិសេសសិទ្ធិទទួលបានកិច្ចពិភាក្សាតទល់គ្នា សិទ្ធិក្នុងការការពារខ្លួន និងសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី។

3. វិធាន ៧៣(គ) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះមានយុត្តាធិការលើ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធាន៧៤ នៃវិធានផ្ទៃក្នុង"។ ប៉ុន្តែ វិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ចែងថា *ជនត្រូវចោទ ឬជនជាប់ចោទ* អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែល "បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង[ទាំងនេះ]"។ វិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ចែងបន្ថែមថា៖

> "១០. នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា *ជនត្រូវចោទ* ឬដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ *ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍។*" (គូសបញ្ជាក់បន្ថែម)

4. វិធានទាំងនេះ ត្រូវបានបកស្រាយដោយពិនិត្យទៅលើគោលការណ៍ជាសារវន្ត ដូចមានចែងនៅក្នុងវិធាន២១ នៃវិធានផ្ទៃក្នុង ដែលចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> <u>**វិធាន ២១: គោលការណ៍ជាសារវន្ត**</u>
>
> ១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន *ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ* ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង*កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព* ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ក-*ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរព គោលការណ៍ចំពោះមុខហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។*

[...]

ឃ-ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ *ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន* ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។ (គូសបញ្ជាក់បន្ថែម)

អង្គបុរេជំនុំជម្រះបានយល់ឃើញពីមុនរួចហើយថា គោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែល អ.វ.ត.ក ត្រូវបានចងភ្ជាប់កាតព្វកិច្ចដើម្បីអនុវត្ត អនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ("កិច្ចព្រមព្រៀង")[4], មាត្រា ៣៥ (ថ្មី) នៃច្បាប់ អ.វ.ត.ក[5] និងមាត្រា ១៤(៣) នៃ ICCPR[6] អាចតម្រូវ

[4] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣។

[5] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរួមបញ្ចូលទាំងការធ្វើវិសោធនកម្មដែលត្រូវបានប្រកាសឲ្យប្រើកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ អ.វ.ត.ក")។

[6] *សូមមើល ឧទា.* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង០០២") (អបជ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ១៣-១៨, ២៧ ("វាច្បាស់ណាស់ថា មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងថា ជនដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន មានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយរួមទាំងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន [...]។ អានុភាពអនុវត្តរបស់មាត្រា ១៣ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក បានផ្តល់ការណែនាំជាក់លាក់ឲ្យអង្គបុរេជំនុំជម្រះពិចារណាមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ក្នុងសំណុំរឿងនេះ ដោយមិនគិតពីវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវតែពិនិត្យថាតើដីកាដែលរងការជំទាស់នេះ បានបំពាន ឬមិនបានបំពានលើសិទ្ធិទាំងឡាយ

ឱ្យអង្គបុរេជំនុំជម្រះប្រើប្រាស់ការបកស្រាយទូលំទូលាយមួយលើសិទ្ធិប្ដឹងឧទ្ធរណ៍ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងអាចតទល់គ្នាក្នុងរឿងក្ដី ហើយត្រូវរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី[7]។ នៅពេលអង្គហេតុ និងកាលៈទេសៈនៃរឿងក្ដីតម្រូវ អង្គបុរេជំនុំជម្រះបានទទួលយកបណ្ដឹងឧទ្ធរណ៍ ដែលលើកឡើងអំពីបញ្ហាសិទ្ធិជាសារវ័ន្ត ឬ "បញ្ហាធ្ងន់ធ្ងរនៃភាពយុត្តិធម៌" តាមរយៈការប្រើប្រាស់ការបកស្រាយទូលំទូលាយចំពោះបទប្បញ្ញត្តិជាក់លាក់មួយដែលផ្ដល់សិទ្ធិប្ដឹងឧទ្ធរណ៍[8] ឬតាមរយៈការប្រើប្រាស់យុត្តាធិការលើបណ្ដឹងឧទ្ធរណ៍ដែលមិនស្ថិតនៅក្នុងយុត្តាធិការជាក់លាក់របស់ខ្លួន ដោយផ្អែកលើវិធាន ២១ នៃវិធានផ្ទៃក្នុង[9]។

5. យើងកត់សម្គាល់ថា សិទ្ធិប្ដឹងឧទ្ធរណ៍ផ្អែកតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ត្រូវបានរៀបចំសម្រាប់ឱ្យ "ជនត្រូវចោទ" ដូចគ្នានឹងសិទ្ធិស្នើសុំបំពេញកិច្ចស៊ើបសួរផ្អែកតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ បណ្ដឹងឧទ្ធរណ៍នេះជំទាស់យ៉ាងជាក់លាក់ទៅនឹងការបកស្រាយសញ្ញាណនៃ "ជនត្រូវចោទ" ដែលត្រូវបានប្រើប្រាស់ដោយសហចៅក្រមស៊ើប

---

របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលបានការពារដោយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែរឬទេ")។

[7] *សូមមើលឧទា.* សំណុំរឿង០០២ (អបជ១១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារA190/I/20 កថាខណ្ឌ៣៦។ សំណុំរឿង ០០២ (អបជ៧១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណុំសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 ("សាលដីកាលើចម្លើយតបរបស់លោក អៀង សារី" កថាខណ្ឌ១៣។ សំណុំរឿង ០០២ (អបជ១៤) សេចក្ដីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារក្ដីអំពីកំហុសឆ្គងក្នុងការបកប្រែឯកសារ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ០២ ("សេចក្ដីសម្រេចស្ដីពីកំហុសឆ្គងក្នុងការបកប្រែឯកសារ") កថាខណ្ឌ ៣។ សំណុំរឿង ០០២ (អបជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ៤៩។

[8] *សូមមើល ឧទា.* សំណុំរឿង ០០២ (អបជ ៤២) សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី អំពីសិទ្ធិចូលជួប ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨ ឯកសារ A104/II/4 កថាខណ្ឌ ១០។

[9] *សូមមើល ឧទា.* សំណុំរឿង ០០២ (អបជ ៤២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣-១៤។ សាលដីកាលើចម្លើយតបរបស់ អៀង សារី កថាខណ្ឌ១៣ *និង* សេចក្ដីសម្រេចស្ដីពីកំហុសឆ្គងក្នុងការបកប្រែ កថាខណ្ឌ ២-៦។

អង្កេតអន្តរជាតិ[10] ហើយបណ្តឹងឧទ្ធរណ៍នេះលើកឡើងថា សិទ្ធិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ [redacted] តម្រូវថា គាត់ត្រូវទទួលបានការអនុញ្ញាតឱ្យចូលរួមកិច្ចស៊ើបសួរនៅកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលនេះ ហើយដោយមូលហេតុនេះ មេធាវីរបស់គាត់ត្រូវទទួលការអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង។ ទោះបីជាដីកាសម្រេចដែលរងការជំទាស់មិនបានបដិសេធចោលសំណើសុំបំពេញកិច្ចស៊ើបសួរដោយផ្ទាល់ដែលសំណើបែបនេះត្រូវបានអនុញ្ញាតនៅក្រោមវិធានផ្ទៃក្នុង ដីកាសម្រេចនេះមានអនុភាពរារាំង [redacted] មិនឱ្យស្នើសុំ *បំពេញកិច្ចស៊ើបសួរណាមួយ* នៅក្នុងកាលៈទេសៈជាច្រើនដែលដីកាសម្រេចនេះត្រូវបានចោទប្រកាន់ថាបានដកហូតកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងតទល់គ្នាពី [redacted]។ យើងយល់ឃើញថា កាលៈទេសៈពិសេសផ្សេងៗនៃរឿងក្តីនេះ តម្រូវឱ្យធ្វើការបកស្រាយទូលំទូលាយអំពីសិទ្ធិប្តឹងឧទ្ធរណ៍ផ្អែកតាមវិធាន ៧៤(៣)(ខ) ដោយពិចារណាអំពីគោលការណ៍សារវ័ន្តដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង។

6. ហេតុដូច្នេះ យើងយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។

## II. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

### ក. ថាតើចៅក្រមសហស៊ើបអង្កេតអន្តរជាតិ ភ័ន្តច្រឡំក្នុងការពិចារណាឡើងវិញលើសេចក្តីជូនដំណឹងចុះថ្ងៃទី ២៩ ខែ កុម្ភៈ ដែរឬយ៉ាងណា។

7. នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាឡើងវិញលើផ្នែកនានានៃសេចក្តីជូនដំណឹងចុះថ្ងៃទី ២៩ ខែ កុម្ភៈ ដែលអនុញ្ញាតឱ្យ [redacted] ពិនិត្យមើលសំណុំរឿង និងលុបចោលការជូនដំណឹងទាំងនោះ។ គាត់ធ្វើបែបនេះដោយផ្អែកលើការរកឃើញរបស់គាត់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងដែលកាន់តំណែងនៅពេលនោះ បាន

---

[10] *សូមមើល ក្នុងចំណោមចំណុចផ្សេងទៀត* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១ (លើកឡើងថា [redacted] គួរត្រូវបានចាត់ទុកថាជាកម្មវត្ថុនៃ "បទចោទព្រហ្មទណ្ឌ" ដោយផ្អែកលើទស្សនៈសារធាតុនោះ)។

វំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការផ្ដល់សិទ្ធិឱ្យ [redacted] ដែលក្នុងនាមជាជនសង្ស័យ គាត់មិនមានសិទ្ធិនោះទេ អនុលោមតាមវិធានផ្ទៃក្នុង និងមិនបានផ្ដល់យុត្តិកម្មណាមួយនោះទេ[11]។

8. [redacted] ជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិភ័ន្តច្រឡំក្នុងការលុបចោលសិទ្ធិពិនិត្យមើលសំណុំរឿងដែលគាត់មានរួចហើយ ដោយមិនបានផ្ដល់ឱកាសឱ្យគាត់ដាក់សារណានោះទេ[12]។ គាត់ជំទាស់បន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានភ័ន្តច្រឡំនៅក្នុងការបកស្រាយ និងការអនុវត្តអំណាចរបស់ខ្លួន ក្នុងការពិចារណាឡើងវិញលើសេចក្ដីសម្រេចពីមុន ដោយហេតុថា "សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមែនជាស្ថាប័នតុលាការដែលសម្រេចចុងក្រោយនោះទេ ហើយគាត់ព្យាយាមប្រើប្រាស់អំណាចនេះ ជាឯកតោភាគី ដោយមិនមានការគាំទ្រពីដៃគូរបស់គាត់ គឺសហចៅក្រមស៊ើបអង្កេតជាតិ ដើម្បីច្រានចោលសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមុន ដែលជាចំណុចស្នូលនៃភាពយុត្តិធម៌សម្រាប់ដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៤"[13]។ ជាចុងក្រោយ [redacted] អះអាងថា ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បិទទុកជាបណ្ដោះអាសន្នចំពោះសេចក្ដីជូនដំណឹងចុះថ្ងៃទី ២៩ ខែ កុម្ភៈ ជាជាងប្រកាសថា សេចក្ដីជូនដំណឹងនោះ ចាត់ទុកជាមោឃៈ ឬគ្មានសុពលភាព *តាំងពីដើមដំបូងមក* (*ab initio*)[14] ដូចនេះមេធាវីរបស់គាត់ "គួរតែមានលទ្ធភាពចូលមើលសំណុំរឿង យ៉ាងហោចណាស់ក៏រហូតដល់ថ្ងៃ[ចេញដីកាសម្រេចដែលរងការជំទាស់]"[15]។

9. អង្គបុរេជំនុំជម្រះបានទទួលស្គាល់ពីមុននូវអំណាច ដែលជាប់មកជាមួយរបស់ស្ថាប័នតុលាការ អ.វ.ត.ក នៅក្នុងការពិចារណាឡើងវិញលើសេចក្ដីសម្រេចពីមុនរបស់ស្ថាប័នទាំងនោះ នៅពេលដែលកាលៈទេសៈប្រែប្រួល ឬនៅពេលដែលខ្លួនយល់ឃើញថា សេចក្ដីសម្រេចលើកមុនមានកំហុស ឬបណ្ដាលឱ្យមានភាពអយុត្តិធម៌[16]។ ទោះបីជាការពិចារណាឡើងវិញអាចធ្វើឡើង*តាម*

---

[11] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤៩។

[12] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៧។

[13] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៨។

[14] នៅក្នុងបរិបទនេះ ពាក្យពេចន៍នេះ មានន័យថា "តាំងពីដើមដំបូងមក"។

[15] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣០។

[16] *សូមមើល ឧទា.* សំណុំរឿង០០២ (អបជ០៣) សេចក្ដីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ C22/I/68 កថាខណ្ឌ២៥។ សំណុំរឿង ០០២ (អបជ ៧៣ និងអបជ ផ្សេងទៀត) សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹង

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

*ការផ្តួចផ្តើមរបស់ចៅក្រមក្តី (proprio motu)*[17] គោលការណ៍យុត្តិធម៌ធម្មជាតិ និងភាពយុត្តិធម៌ផ្នែកនីតិវិធី តម្រូវឱ្យភាគីណាមួយ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលសិទ្ធិ ឬផលប្រយោជន៍របស់បុគ្គល ឬភាគីទាំងនោះ អាចរងការប៉ះពាល់ មានសិទ្ធិធ្វើការឆ្លើយតប មុនពេលធ្វើការសម្រេចបែបនេះ[18]។

---

ដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ១០៦។ សេចក្តីសម្រេចលើពាក្យសុំការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនៅក្នុងសំណុំរឿង "ឌុច" ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/41 កថាខណ្ឌ៦ និង ៧។ សំណុំរឿង ០០២ (អបជ ២៤/២៥) សេចក្តីសម្រេចលើសំណើសុំឱ្យពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេច ទាក់ទងនឹងសំណើសុំឱ្យមានសវនាការ ដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ D164/4/9 កថាខណ្ឌ ១២។

[17] នៅក្នុងបរិបទនេះ មានន័យថា ផ្អែកលើការផ្តួចផ្តើមរបស់ចៅក្រម។

[18] *សូមមើល រដ្ឋអាជ្ញា តទល់នឹង Nzabonimana,* ICTR-98-44D-AR7Bis សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំស្តីពីដីកាសម្រេចបដិសេធចោលសេចក្តីសម្រេចចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១០ និងសេចក្តីសម្រេចលើសំណើសុំអនុញ្ញាតប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់ប្រធានចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១០ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ២៩ ("ទោះបីជាអង្គជំនុំជម្រះសាលាដំបូង អាចសម្រេច *តាមគំនិតផ្តួចផ្តើម* ដើម្បីពិចារណាលើសេចក្តីសម្រេចរបស់ខ្លួន ក៏ការសម្រេចនេះមិនបានធ្វើឱ្យអង្គជំនុំជម្រះរួចផុតពីកតាព្វកិច្ចស្តាប់សក្ខីកម្មភាគី ដែលសិទ្ធិរបស់ភាគីនោះ អាចនឹងប៉ះពាល់ដោយការពិចារណាឡើងវិញនេះ") *និង* សំណុំរឿងលេខ ០០២ (អបជ ៤៧) សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ១១៧ *ជាមួយគ្នានឹង* សេចក្តីណែនាំស្តីពីការពិចារណាឡើងវិញលើភាពអាចទទួលយកបាននៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D250/3/2/1/6 (នៅពេលដែលអង្គបុរេជំនុំជម្រះបានចាប់ផ្តើម *តាមការផ្តួចផ្តើមតាមចៅក្រម* លទ្ធភាពពិចារណាលើសេចក្តីសម្រេចពីមុនដែលប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែ អង្គជំនុំជម្រះបានយល់ឃើញថា ខ្លួនមិនអាចធ្វើសេចក្តីសម្រេចណាមួយដោយមិនស្តាប់ទស្សនៈផ្សេងៗ *រួមទាំង*ជនជាប់ចោទទេ ហេតុដូច្នេះអង្គបុរេជំនុំជម្រះបង្គាប់ឱ្យភាគីដាក់សារណា)។ *សូមមើល* ជាទូទៅទាក់ទងនឹងសិទ្ធិស្តាប់សក្ខីកម្ម មុនពេលសេចក្តីសម្រេចមួយដែលប៉ះពាល់ដល់សិទ្ធិ ត្រូវបានធ្វើឡើង៖ សំណុំរឿង ០០២ (អ.ជ.ត.ក ១៨) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13 កថាខណ្ឌ ៤២ ("ភាពចាំបាច់ក្នុងការគោរពសិទ្ធិផ្តល់ចម្លើយនៅក្នុងការជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ [...] ត្រូវធ្វើឡើងដោយផ្អែកលើភាពសមហេតុផល និងផលប្រយោជន៍យុត្តិធម៌ដ៏មានអត្ថន័យ និងស្របទៅតាមបទដ្ឋានគតិយុត្តិអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែល")។ តុលាការយុត្តិធម៌អន្តរជាតិ *ប្រទេសអូស្ត្រាលី តទល់នឹង ប្រទេសបារាំង* សាលក្រម (រឿងក្តីទាក់ទិននឹងការសាកល្បងនុយក្លេអ៊ែរ៖ មតិយោបល់ជំទាស់របស់

10. ក្នុងរឿងក្តីបច្ចុប្បន្ននេះ សេចក្តីសម្រេចដើម្បីពិចារណាឡើងវិញទៅលើសេចក្តីជូនដំណឹង ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ត្រូវបានជំរុញឡើងដោយសំណើជាថ្មីម្តងទៀតពី [redacted] សុំការអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង។ [redacted] ដែលអាចរំពឹងដោយត្រឹមត្រូវថា សេចក្តីជូនដំណឹងកាលពីថ្ងៃទី ២៩ ខែ កុម្ភៈ មានសុពលភាព និងជាការជូនដំណឹងចងកាតព្វកិច្ចផងនោះ បានស្នើសុំជាច្រើនលើកថា ការ

---

ចៅក្រម Sir Garfield Barwick) ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៧៤ ទំព័រ ៣៩១ ("នៅគ្រប់ករណី អ្នកដាក់ពាក្យសុំត្រូវទទួលបានសិទ្ធិដាក់សារណាទាក់ទិននឹងបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់តុលាការ")។ ការលើកឡើងនេះមិនស្ថិត *នៅក្នុង* ការជំទាស់ទៅនឹងមតិយោបល់ភាគច្រើននោះទេ។ មតិយោបល់ខ្វែងគ្នាគឺផ្អែកលើការយល់ឃើញផ្សេងៗគ្នានៃស្ថានភាពរបស់រឿងក្តី។ *សូមមើល* កថាខណ្ឌ៣៣ នៃមតិយោបល់ភាគច្រើន)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Jelistic,* IT-95-10-A, សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ២៧ ("ការដែលថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិសម្រេច *តាមការផ្តួចផ្តើមរបស់ខ្លួន* ដែលផ្តល់ឱ្យអង្គជំនុំជម្រះនូវសិទ្ធិធ្វើសេចក្តីសម្រេច ទោះបីជាភាគីស្នើសុំ ឬមិនស្នើសុំឱ្យធ្វើសេចក្តីសម្រេចក៏ដោយ។ ប៉ុន្តែ ការដែលថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ*តាមការផ្តួចផ្តើមរបស់ខ្លួន* មិនបានធ្វើឱ្យអង្គជំនុំជម្រះរួចផុតពីកាតព្វកិច្ចតុលាការក្នុងការស្តាប់សក្ខីកម្មភាគី ដែលសិទ្ធិរបស់ភាគីអាចនឹងប៉ះពាល់ដោយសេចក្តីសម្រេចនោះ")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Perisic,* IT-04-81-T, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំឱ្យពិចារណាឡើងវិញអំពីឯកសារដែលទទួលយកតាមការផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង I ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៦ និង ១៥ (អង្គជំនុំជម្រះសាលាដំបូងទទួលពិចារណាឡើងវិញលើសេចក្តីសម្រេចពីមុនរបស់ខ្លួនក្នុងការទទួលយកភ័ស្តុតាងថ្មី*តាមការផ្តួចផ្តើមរបស់ខ្លួន* ដោយសារតែអង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តី "គួរតែទទួលបានឱកាសសមហេតុផលមួយដើម្បីជំទាស់ទៅនឹងការទទួលយកឯកសារនេះ")។ តុលាការ ECtHR *រឿងក្តី* Niderost-Huber *តទល់នឹង ប្រទេសស្វីស* បណ្តឹងលេខ 18990/91 សាលក្រម ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ កថាខណ្ឌ ២៩ (គូសបញ្ជាក់ថា "ការទុកចិត្តរបស់គូវិវាទនៅក្នុងការស្វែងរកយុត្តិធម៌ [...] ផ្អែកលើ ក្នុងចំណោមនោះ ការយល់ដឹងថា គូវិវាទមានឱកាសលើកឡើងនូវការយល់ឃើញរបស់ខ្លួនទៅលើរាល់ឯកសារនីមួយនៅក្នុងសំណុំរឿង")។ តុលាការជាន់ខ្ពស់ប្រទេសអូស្ត្រាលី *រឿងក្តី Kioa តទល់នឹង West* (១៩៨៥) 159 C.L.R. 550 ត្រង់ចំណុច ៥៨២ (នេះគឺជាវិធានជាមូលដ្ឋាននៃទ្រឹស្តីច្បាប់ទូទៅនៃយុត្តិធម៌ធម្មជាតិ ដែលបានលើកឡើងនៅក្នុងលក្ខខណ្ឌពីបុរាណថា និយាយជាទូទៅ នៅពេលចេញដីកាបង្គាប់មួយ ដែលនឹងដកហូតសិទ្ធិ ឬផលប្រយោជន៍ខ្លះៗរបស់បុគ្គលម្នាក់ ឬការរំពឹងស្របច្បាប់ចំពោះផលប្រយោជន៍ បុគ្គលនោះមានសិទ្ធិដឹងអំពីរឿងក្តីដែលប្តឹងប្រឆាំងលើរូបគាត់ ហើយបុគ្គលនោះត្រូវបានផ្តល់ឱកាសឱ្យឆ្លើយតបទៅនឹងបណ្តឹងនោះ [...])។ ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសបារាំង មាត្រា ១៦ (ទោះក្នុងកាលៈទេសៈណាក៏ដោយ ចៅក្រមត្រូវបង្គាប់ឱ្យភាគីគោរព និងត្រូវគោរពដោយខ្លួនឯង នូវគោលការណ៍ចំពោះមុខ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចៅក្រមអាចទទួលយកទឡ្ហីករណ៍ សេចក្តីពន្យល់ និងឯកសារដែលភាគីបានលើកឡើង ឬបង្ហាញតែក្នុងករណីភាគីមានលទ្ធភាពពិភាក្សាដេញដោលចំពោះមុខប៉ុណ្ណោះ។ ចៅក្រមមិនអាចផ្អែកសេចក្តីសម្រេចរបស់ខ្លួនលើទឡ្ហីករណ៍ច្បាប់ ដែលខ្លួនដកស្រង់យកដោយបញ្ញត្តិ ដោយមិនបានស្នើឱ្យភាគីបង្ហាញសេចក្តីសង្កេតជាមុនឡើយ)។ Stefan Trechsel, *សិទ្ធិមនុស្សនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ,* Oxford University Press, ២០០៦ ទំព័រ ៨៩ ("សេចក្តីសម្រេចមិនអាចធ្វើឡើងនោះទេ ប្រសិនបើបុគ្គលពាក់ព័ន្ធ មិនត្រូវបានផ្តល់ឱកាសជាមុនឱ្យលើកឡើងជំហររបស់ខ្លួនលើបញ្ហានេះ")។

ជូនដំណឹងនោះត្រូវតែយកមកអនុវត្តដើម្បីបញ្ជាក់អំពីសិទ្ធិដែលបានផ្តល់ជូននាពេលនេះ[19]។ ជាការឆ្លើយតប សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកហូតសិទ្ធិអាចចូលពិនិត្យមើលសំណុំរឿងដែលត្រូវបានអនុញ្ញាតកាលពីមុនមកហើយ ដោយមិនបានផ្តល់ឱ្យ [redacted] នូវការជូនដំណឹងណាមួយជាមុន និងមិនបានផ្តល់លទ្ធភាពអាចឱ្យគាត់ដាក់សំណើសុំនានាទាក់ទងទៅនឹងបញ្ហានេះបានទេ។ ការធ្វើបែបនេះបានបណ្តាលឱ្យសេចក្តីសម្រេចដើម្បីពិចារណាឡើងវិញទៅលើសេចក្តីជូនដំណឹង ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ធ្វើឡើងដោយរំលោភទៅលើគោលការណ៍ស្តីពីសច្ចភាពផ្លូវច្បាប់[20] យុត្តិធម៌ធម្មជាតិ និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដែលតាមរយៈនេះ បណ្តាលឱ្យមានការប៉ះពាល់ដល់ [redacted]។ អាស្រ័យហេតុនេះ យើងយល់ឃើញថា សេចក្តីសម្រេចដែលត្រូវបានជំទាស់នេះគួរត្រូវបានកែប្រែដោយសារសេចក្តីសម្រេចនេះពិចារណាឡើងវិញទៅលើផ្នែកខ្លះនៃការជូនដំណឹង ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ដែលអនុញ្ញាតឱ្យ [redacted] មានសិទ្ធិពិនិត្យមើលសំណុំរឿង ហើយបញ្ហានេះគួរត្រូវបានបញ្ជូនត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចសាជាថ្មីទៅលើបញ្ហានៃការពិចារណាឡើងវិញនេះ ក្រោយពីបានផ្តល់ឱកាសឱ្យ [redacted] និងភាគីពាក់ព័ន្ធឱ្យផ្តល់ចម្លើយរួចមក និងពិចារណាទៅលើគោលការណ៍ ដែលបានកំណត់នៅក្នុងផ្នែកនៃយោបល់នេះខាងក្រោម ដែលដោះស្រាយទៅលើអង្គសេចក្តីនៃសំណើរបស់ [redacted] សុំពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ។

**ខ. ថាតើសហចៅក្រមស៊ើបអង្កេតភ័ន្តច្រឡំក្នុងការបដិសេធសំណើសុំពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេតដែរឬអត់**

11. នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញថា [redacted] មិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ឬចូលរួមក្នុងការស៊ើបអង្កេតនោះទេ ដោយសារតែគាត់មិនមែនជា "ជនត្រូវចោទ" នៅក្នុងកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០៤ នោះទេ។ ជាពិសេស សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញថា វិធានផ្ទៃក្នុងបានរក្សាសិទ្ធិទាំងនេះ*ផ្តាច់មុខ* ជូន "សហព្រះរាជអាជ្ញា និង '*មេធាវីរបស់ភាគីទាំងអស់*' ដែលជា ជនត្រូវចោទ

[19] *សូមមើល* សំណើសុំពិនិត្យសំណុំរឿង កថាខណ្ឌ ៣-៤ និង កថាខណ្ឌ ៨។

[20] *សូមមើល* វិធាន ២១(១) នៃវិធានផ្ទៃក្នុងដែលចែងថា៖ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ត្រូវតែបកស្រាយដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់។

ជនជាប់ចោទ និងភាគីដើមបណ្តឹងរដ្ឋប្បវេណី[21]” ហើយមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានធានាស្រដៀងគ្នានេះចំពោះការផ្តល់សិទ្ធិឱ្យចូលពិនិត្យមើលសំណុំរឿងនេះឱ្យទៅ “ជនទាំងឡាយដែលត្រូវចោទប្រកាន់”[22]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាឃើញថា [redacted] មិនមែនជា “ជនត្រូវចោទ” ដែលស្ថិតនៅក្នុងអត្ថន័យនៃវិធានផ្ទៃក្នុង ឬច្បាប់សិទ្ធិមនុស្សនោះទេ ដោយសារថា គាត់មិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការ ដោយអនុលោមតាមនីតិវិធីដែលបានកំណត់នៅក្នុងវិធាន ៥៧ នោះទេ ហើយមិនមានសេចក្តីសម្រេចថាតើមាន “តម្រុយច្បាស់លាស់ និងស៊ីចង្វាក់គ្នាថា [គាត់] អាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញានៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែរឬអត់នៅឡើយទេ”[23]។ បន្ថែមពីលើនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានយល់ឃើញថា “តាមរយៈការទទួលបានការជូនដំណឹងអំពីឋានៈរបស់គាត់ជា ‘ជនសង្ស័យ’ និងអំពីបទចោទប្រកាន់ប្រឆាំងនឹងគាត់ ជនសង្ស័យត្រូវបានទទួលរងប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារតែការដកចេញពីវិធានផ្ទៃក្នុង និងដើម្បីធានាឱ្យមានការផ្តល់សិទ្ធិដែលជនសង្ស័យមិនបានទទួលនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះនៅឡើយ”[24]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានយល់ឃើញថា ទាំងបញ្ហាសុខភាពទ្រុឌទ្រោមរបស់ [redacted] ចំណាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយចំពោះកិច្ចដំណើរការនីតិវិធី ឬ ការចុះជួបរបស់បុគ្គលិកនៃប្រព័ន្ធផ្សព្វផ្សាយ អាចមានផលប៉ះពាល់បែបនោះទេ[25]។ ចុងក្រោយបំផុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា សេចក្តីសម្រេចអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចូលពិនិត្យសំណុំរឿងមិនគាំទ្រដល់សំណើសុំនានានោះទេ ដោយសារថា ដើមបណ្តឹងរដ្ឋប្បវេណីគឺជា “ភាគី” ទៅនឹងកិច្ចដំណើរការនីតិវិធី ឯជនសង្ស័យវិញមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនោះឡើយ”[26]។

---

[21] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣៧។

[22] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣៨។

[23] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៤៤-៤៧។

[24] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៥៥។

[25] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៥៦-៥៨។

[26] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៦០។

12. នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ [redacted] លើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយ “ផ្តោតសំខាន់ទៅលើលក្ខខណ្ឌតម្រូវជាផ្លូវការសម្រាប់ការចោទប្រកាន់នៅ អ.វ.ត.ក ដូចមានចែងនៅក្នុង [វិធានផ្ទៃក្នុង] ជាជាងការពិនិត្យមើល ថាតើ [redacted] គួរត្រូវបានចាត់ទុកថាជាកម្មវត្ថុនៃ “បទចោទព្រហ្មទណ្ឌ” ដោយផ្អែកលើទស្សនៈផ្នែកអង្គសេចក្តីដែរឬអត់នោះ”[27]។ ជាពិសេស [redacted] បានអះអាងថា គាត់ជាកម្មវត្ថុនៃ “បទចោទព្រហ្មទណ្ឌ” ដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្ស[28] ដោយសារគាត់ “បានដឹងជាផ្លូវការនូវកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់” នៅពេលដែលគាត់បានទទួលការជូនដំណឹងកាលពីថ្ងៃទី ២៩ ខែ កុម្ភៈ រួចមក[29]។ [redacted] ក៏បានលើកឡើងថា គាត់ត្រូវបាន “ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ” ដោយការស៊ើបសួរ ដោយហេតុថា អាជ្ញាធររបស់ អ.វ.ត.ក “បានទៅទំនាក់ទំនង” ជាមួយគាត់កាលពីថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២[30] ហើយតំណាងរបស់អង្គភាពគាំពារការការពារក្តីក៏បានទៅជួបគាត់ ក្នុងគោលបំណងជួយសម្របសម្រួលដល់ការជ្រើសរើសមេធាវីរបស់គាត់។ ហើយក្រោយមក មេធាវីរបស់គាត់ក៏បានទៅជួបគាត់ និងបានសម្ភាសន៍ជាមួយគាត់ ហើយគាត់បានផ្តល់ព័ត៌មានដល់មេធាវីរបស់គាត់វិញ ដែលនាំឱ្យឈានដល់ការស៊ើបអង្កេតមួយប្រកបដោយសក្តានុពល ដែលអាចនាំឱ្យមានការផ្តល់ភស្តុតាងដោះបន្ទុកបានផង[31]។ [redacted] បានជំទាស់តវ៉ាថា ដោយសារ “[គាត់] ជាកម្មវត្ថុនៃ “ការចោទប្រកាន់ពីបទឧក្រិដ្ឋ” គាត់ត្រូវបានធានានូវសិទ្ធិដែលភ្ជាប់ទៅនឹងឋានៈរបស់ “ជនត្រូវចោទ” រួមទាំងសិទ្ធិអាចចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរផងដែរ[32]។

13. [redacted] ក៏បានលើកឡើងនូវទឡ្ហីករណ៍មួយចំនួនបន្ថែមទៀត ដែលគាត់អះអាងថា ជាមូលហេតុនាំឱ្យគាត់ទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរនេះ។ ទីមួយ គាត់ជំទាស់ទៅលើការចុះផ្សាយរបស់សារព័ត៌មានចំពោះសំណុំរឿង ០០៤ ក្រោយពីមានការរំលោភទៅលើភាពសម្ងាត់នៃកិច្ចស៊ើបសួរដែលមានប្រភពចេញមកពី អ.វ.ត.ក ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបាននូវសច្ចធារណ៍នៃនិរទោស និងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សុខភាព

---

27 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។

28 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤២។

29 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៩។ *សូមមើលផងដែរ* កថាខណ្ឌ ៣៨។

30 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥១។

31 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥២។

32 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៥។

ទ្រុនទ្រោមរបស់គាត់ ហើយហេតុដូច្នេះ តម្រូវឱ្យផ្តល់ព័ត៌មានអំពីការចោទប្រកាន់មកលើរូបគាត់នៅក្នុងសារព័ត៌មាន និងតម្រូវផ្តល់ឱកាសឱ្យគាត់ដើម្បីធ្វើការឆ្លើយតបទៅវិញ[33]។ ទីពីរ [redacted] អះអាងថា គាត់ត្រូវបានដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពលំបាកយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងសហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលបានសិទ្ធិចូលមើលសំណុំរឿង និងមានឱកាសមានឥទ្ធិពលមកលើលទ្ធផលនៃកិច្ចស៊ើបសួរ ដែលស្ថានភាពនេះបណ្តាលឱ្យរំលោភលើគោលការណ៍ស្តីពីសមភាពនៃគូក្តី។ ទាក់ទងនឹងចំណុចនេះ គាត់ជំទាស់ថា ការបំពេញកិច្ចស៊ើបសួរដោយមិនមាន "ការចែករំលែកព័ត៌មាន ឬការពិនិត្យពិច័យពីសំណាក់មេធាវីការពារក្តី" អស់រយៈពេលជាងពីរឆ្នាំកន្លងមក ចាប់តាំងពីមានសំណើសុំពិនិត្យមើលសំណុំរឿងលើកទីមួយក្នុងឆ្នាំ ២០១១ ធ្វើឱ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីទាំងមូល[34]។ [redacted] ក៏លើកឡើងផងដែរថា វិសមភាពខាងនីតិវិធីរវាងភាគីបដិបក្ខកាន់តែត្រូវបានធ្វើឱ្យមានភាពធ្ងន់ធ្ងរឡើងៗ តាមរយៈសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលមើលសំណុំរឿង[35] ដែលបង្ហាញឱ្យឃើញនូវភាពផ្ទុយគ្នាដែលមានមកជាមួយស្រាប់ ចំពោះការបកស្រាយវិធានផ្ទៃក្នុង[36] ងាកចេញពីគោលការណ៍ទាំងឡាយដែលបានអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ជាតិ[37] និងធ្វើឱ្យប៉ះពាល់ដល់ភាពសម្ងាត់នៃការស៊ើបអង្កេត[38]។ ទីបី [redacted] អះអាងថា "បើទោះបីជាមានមូលដ្ឋានច្បាប់សម្រាប់ការរឹតបន្តឹងសិទ្ធិរបស់គាត់ក្នុងការចូលមើលសំណុំរឿងក៏ដោយ" ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវតែបង្ហាញថា ការរឹតត្បិតទៅលើសិទ្ធិជាមូលដ្ឋានដើម្បីការពារដល់ផលប្រយោជន៍ស្របច្បាប់ ត្រូវតែសមាមាត្រទៅនឹងផលប្រយោជន៍នៅចំពោះមុខ និងអាចប៉ះពាល់ក្នុងកម្រិតអប្បបរមាដល់សិទ្ធិនោះ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញបែបនេះទេ[39]។ ជាចុងក្រោយ [redacted] ជំទាស់តវ៉ាថា ការខកខានមិនបានផ្តល់សិទ្ធិឱ្យគាត់ចូលមើលសំណុំរឿង បានដកហូតសិទ្ធិរបស់គាត់ដែលត្រូវ

---

[33] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៦-៦០។

[34] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៦។

[35] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧០។

[36] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧១។

[37] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧២-៧៣។

[38] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៤។

[39] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៥-៧៧។

ទទួលបានការការពារប្រកបដោយប្រសិទ្ធភាពពីសំណាក់មេធាវីការពារក្តី ដែលជាសិទ្ធិមួយត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[40]។

14. យើងកត់សម្គាល់ឃើញថា មិនមានការជំទាស់តវ៉ាថា វិធានផ្ទៃក្នុងផ្តល់សិទ្ធិឱ្យចូលរួមក្នុងការស៊ើបអង្កេត និងមានសិទ្ធិចូលមើលសំណុំរឿង តាមរយៈមេធាវីដល់ "ជនត្រូវចោទ" ដែលត្រូវបានចាត់ទុកថាជា "ភាគីនៃកិច្ចដំណើរការនីតិវិធី" នៅចំពោះមុខ អ.វ.ត.ក នោះទេ[41]។ ក៏មិនមានការជំទាស់ផងដែរថា សហចៅក្រមស៊ើបអង្កេតមិនទាន់បានសម្រេចនៅឡើយ ថាតើធ្វើការចោទប្រកាន់ជាផ្លូវការប្រឆាំងនឹង [redacted] ដោយអនុលោមតាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុងដែរឬអត់នោះ ហើយក៏មិនបានកោះហៅគាត់ឱ្យចូលខ្លួនជាលើកដំបូង ស្របតាមវិធាន ៥៧ នោះដែរ។ ក្នុងបរិបទនេះ បណ្តឹងឧទ្ធរណ៍បានស្នើសុំឱ្យមានការពិនិត្យមើលថាតើ [redacted] ដែលត្រូវបានកំណត់ឈ្មោះថាសង្ស័យនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលដាក់ដោយសហព្រះរាជ អាជ្ញាអន្តរជាតិ[42] គឺជា ឬគួរត្រូវបានចាត់ទុកថាជា "ជនត្រូវចោទ" ដែរឬអត់ បើទោះបីជាថានីតិវិធីដែលមានចែងក្នុងវិធាន ៥៥(៤) និង ៥៧ នៃវិធានផ្ទៃក្នុង មិនត្រូវបានបំពេញដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូបនោះក្តី។

15. នៅដើមដំបូង យើងកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងមិនបានចែងឱ្យបានច្បាស់លាស់ទាល់តែសោះ ចំពោះនិយមន័យនៃពាក្យ "ជនត្រូវចោទ" និង "ជនសង្ស័យ" ហើយអត្ថន័យពិតប្រាកដ និងផលវិបាកនៃដំណើរការចោទប្រកាន់ មានចែងនៅក្នុងវិធាន ៥៥(៤) និងវិធាន ៥៧ នៃវិធានផ្ទៃក្នុង។ ភាពមិនច្បាស់លាស់នេះត្រូវបានបង្ហាញដោយការបកស្រាយផ្ទុយគ្នាចំពោះសញ្ញាណនៃពាក្យ "ជនត្រូវចោទ" ដែលត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតជាលើកដំបូងនៅក្នុងសំណុំរឿង ០០២ និងក្រោយមក នៅក្នុងសំណុំរឿង ០០៣ និង ០០៤។ ម្យ៉ាង សទ្ទានុក្រមនៃវិធានផ្ទៃក្នុងកំណត់និយមន័យនៃពាក្យ "ជនត្រូវចោទ" យ៉ាងច្បាស់លាស់ថាជា "បុគ្គលណាម្នាក់ដែលជាកម្មវត្ថុនៃការចោទប្រកាន់នៅក្នុងរឿងក្តីជាក់លាក់ណាមួយ ក្នុងចន្លោះពីពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររហូតដល់ពេលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែង

[40] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៩។

[41] *សូមមើល* ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ៣៧ *ដែលយោងទៅលើ* វិធាន ៥៥(៦) ៥៥(៨) ៥៥(១១) និង ៦០ និងយោងទៅលើនិយមន័យនៃពាក្យថា "ភាគី" នៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុង។

[42] ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥។

ការចោទប្រកាន់”។ ម្យ៉ាងវិញទៀត វិធានផ្ទៃក្នុងកំណត់និយមន័យនៃពាក្យ “ជនសង្ស័យ” ថាជា “បុគ្គលណាម្នាក់ដែលសហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា អាចបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ប៉ុន្តែ មិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ”។ កន្លងមក ពាក់ព័ន្ធទៅនឹងដំណើរការ “ចោទប្រកាន់” ជាផ្លូវការនោះ វិធាន ៥៥(៤) នៃចែងថា៖

> សហចៅក្រមស៊ើបអង្កេតមានអំណាចបើកការស៊ើបសួរ ប្រឆាំងនឹងជនទាំងឡាយណាដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំង នោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតត្រូវ សួរយោបល់សហព្រះរាជអាជ្ញា មុនពេលដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ។

វិធាន ៥៧ ចែងអំពីដំណើរការសម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតប្រាប់*ជនត្រូវចោទ* ជាផ្លូវការអំពីបទចោទប្រកាន់ប្រឆាំងនឹងរូបគេ នៅក្នុងពេល “ចូលមកបង្ហាញខ្លួនជាលើកដំបូង”។

16. នៅក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេត ដែលបានផ្អែកទៅលើនិយមន័យនៃពាក្យថា “ជនត្រូវចោទ” បានយល់ឃើញថា [ជនណាដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានគេហៅថា “*ជនត្រូវចោទ*”][43]។ សហចៅក្រមស៊ើបអង្កេតទាំងពីររូប បានពង្រីកអំណាចរបស់ពួកគាត់ ក្នុងការកំណត់បទចោទឱ្យបានជាក់លាក់ចំពោះជនណាម្នាក់ដែលអាចត្រូវបានចោទប្រកាន់ និងការទទួលបានឋានៈជា “ជនត្រូវចោទ”[44]។ ការបកស្រាយរបស់សហចៅក្រម

[43] ដីកាសម្រេចបដិសេធការដាក់ឱ្យស្ថិតនៅក្រុមការពិនិត្យបន្ថែម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារលេខ D 298/2 (“ដីកាសម្រេចបដិសេធការដាក់ឱ្យស្ថិតនៅក្រុមការពិនិត្យបន្ថែម”) ជើងទំព័រយោងលេខ ៦។ *សូមមើល ផងដែរ* កថាខណ្ឌ ១៣។

[44] *សូមមើល* ដីកាសម្រេចបដិសេធការដាក់ឱ្យស្ថិតនៅក្រុមការពិនិត្យបន្ថែម កថាខណ្ឌ ១៣ *និង* ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺអំពីបទចោទ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ D198/1 (“ដីកាស្តីពីការបំភ្លឺអំពីបទចោទ”) កថាខណ្ឌ ១០-១១ និងសេចក្តីសន្និដ្ឋាន។ យើងកត់សម្គាល់ឃើញថា សេចក្តីយោងនៅក្នុងសេចក្តីសម្រេចដែល

ស៊ើបអង្កេតទាំងពីរបានយោង និងបានឆ្លុះបញ្ចាំងពីជំហរដែលបានមាននៅក្នុងច្បាប់បារាំង មុនពេលកំណែទម្រង់តុលាការត្រូវបានអនុម័តនៅឆ្នាំ ១៩៩៣[45]។ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ រួមទាំងសេចក្តីសម្រេចដែលត្រូវបានជំទាស់ សហចៅក្រមស៊ើបអង្កេតបានសង្កត់ធ្ងន់ទៅលើនិយមន័យនៃពាក្យថា "ជនសង្ស័យ" ដែលសហចៅក្រមស៊ើបអង្កេតបានញែកដាច់ពីឋានៈរបស់ "ជនត្រូវចោទ" ដោយយោងទៅលើការកើតមានឡើងនៃដំណើរការ "ចោទប្រកាន់"ជាផ្លូវការ។ ជាលទ្ធផល សហចៅក្រមស៊ើបអង្កេតបានកំណត់និយមន័យនៃពាក្យ "ជនត្រូវចោទ" ដោយយោងទៅលើលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីសម្រាប់ការចោទប្រកាន់ ដែលស្ថិតនៅក្រោមវិធាន ៥៥ (៤) និង ៥៧ នៃវិធានផ្ទៃក្នុង ដែលនាំឱ្យពួកគាត់យល់ឃើញថា បុគ្គលណាម្នាក់មានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទទួលបានឋានៈជា "ជនត្រូវចោទ" តែនៅពេលដែលត្រូវបានចោទប្រកាន់ជាផ្លូវការដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងអំឡុងពេលចូលមកបង្ហាញខ្លួនជាលើកដំបូងតែប៉ុណ្ណោះ[46]។ ដោយយោងទៅលើមូលហេតុដូចបានលើកឡើងខាងក្រោមនេះ យើងយល់

---

ត្រូវបានជំទាស់ រហូតដល់ដីកាស្តីពីការបំភ្លឺអំពីបទចោទ ដើម្បីគាំទ្រការបកស្រាយសញ្ញាណនៃពាក្យថា "ជនត្រូវចោទ" ដែលបានសម្រេចនាពេលនោះ មានការយល់ច្រលំ។ ខណៈដែលសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និងសហចៅក្រមស៊ើបអង្កេត LEMONDE បានលើកឡើងនៅក្នុងសំណុំរឿង ០០២ ថា ពួកគាត់ "មានអំណាច" ប៉ុន្តែ មិនមានកាតព្វកិច្ចដើម្បីធ្វើការចោទប្រកាន់ជនណាម្នាក់នោះទេ ទោះបីជាជននោះមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ឬមិនមានក៏ដោយ"។ សហចៅក្រមស៊ើបអង្កេតទាំងពីររូបកំពុងតែយោងទៅលើអំណាចរបស់ខ្លួន ក្នុងការជូនដំណឹងជាផ្លូវការទៅ *ជនត្រូវចោទទាំងឡាយ* ក្នុងសំណុំរឿង ០០២ អំពីអង្គហេតុបន្ថែម និងឧក្រិដ្ឋកម្ម ដែលអាចត្រូវបានយកមកចោទប្រកាន់ បន្ទាប់ពីការដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដោយសហព្រះរាជអាជ្ញារួចមក។ សេចក្តីថ្លែងការណ៍នេះមិនមានអ្វីទាក់ទងនឹងការទទួលបានឋានៈរបស់ "ជនត្រូវចោទ" នោះទេ និងគ្រាន់តែបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ បានពិចារណាទៅលើឋានៈរបស់ជនត្រូវចោទថាមានលក្ខណៈឯករាជ្យពីសេចក្តីសម្រេចរបស់ខ្លួនក្នុងការកំណត់បទចោទជាក់លាក់ជាផ្លូវការ នៅពេលយោងដល់បរិបទរបស់វា។

[45] *សូមមើល* ដីកាសម្រេចបដិសេធការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យបន្ថែម កថាខណ្ឌ ១៣ *ដែលសំអាងទៅលើ* សំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ *ព្រឹត្តិប័ត្រសំណុំរឿងព្រហ្មទណ្ឌ*លេខ ៣៤៤ (ដែលសាលាវិនិច្ឆ័យ "Court of Cassation" ប្រទេសបារាំងយល់ឃើញថា ជនណាម្នាក់ដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានចាត់ទុកថាជាជនត្រូវចោទដោយស្វ័យប្រវត្តិ ដោយមិនគិតអំពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីបទចោទនោះឡើយ)។ *សូមមើលផងដែរ* ចំពោះការអនុវត្តដូចគ្នានេះ៖ សំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៣ *ព្រឹត្តិប័ត្រសំណុំរឿងព្រហ្មទណ្ឌ* ឆ្នាំ ១៩៧៣ លេខ ១៩០ ទំព័រ *៤៥៥ និង* សំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧១ *ព្រឹត្តិប័ត្រសំណុំរឿងព្រហ្មទណ្ឌ* ឆ្នាំ ១៩៧១ លេខ ១៧១ ទំព័រ ៤២៨។

[46] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣៦-៣៧ និង ៤០-៤៤។

ឃើញថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០២ ដែលថា ជនសង្ស័យមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានចាត់ទុកថា "ជនត្រូវចោទ" ត្រូវយកជាបានការ។

17. ទីមួយ យើងកត់សម្គាល់ឃើញថា ឋានៈរបស់ "ជនសង្ស័យ" និង "ជនត្រូវចោទ" មិនត្រូវបានកំណត់និយមន័យឱ្យជាប់ទាក់ទងគ្នានោះទេ។ ហេតុដូច្នេះ មិនមានការបញ្ជាក់ថា ពាក្យទាំងពីរនេះត្រូវជាប់ទាក់ទងគ្នាទាំងស្រុងនោះទេ[47]។ តាមពិតទៅ បុគ្គលម្នាក់អាចស្ថិតនៅក្នុងរង្វង់និយមន័យទាំងពីរក្នុងរយៈពេលជាក់លាក់មួយ ដែលជាលទ្ធផលមិនត្រឹមតែធ្វើឱ្យគាត់ទទួលបានសិទ្ធិដែលកាន់តែមានកម្រិតរបស់ "ជនសង្ស័យ" ប៉ុណ្ណោះទេ ប៉ុន្តែ ក៏ទទួលបានសិទ្ធិទាំងឡាយដែលត្រូវបានផ្តល់ឱ្យទៅ "ជនត្រូវចោទ" ផងដែរ។ ដោយសារ [redacted] អះអាងថា គាត់ត្រូវទទួលបានសិទ្ធិដែលបានភ្ជាប់ទៅនឹងឋានៈរបស់ "ជនត្រូវចោទ" យើងត្រូវសម្រេច ថាតើគាត់ស្ថិតនៅក្នុងវិសាលភាពនៃនិយមន័យជាក់លាក់អំពីឋានៈនេះដែរឬអត់ ដែលត្រូវតែផ្តល់អត្ថន័យឱ្យបានពេញលេញ។ និយមន័យពាក្យថា "ជនត្រូវចោទ" ដែលបានកំណត់នៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុង មិនសំដៅទៅលើដំណើរការ "ចោទប្រកាន់" ណាមួយជាផ្លូវការ ដែលស្ថិតនៅក្រោមវិធាន ៥៥(៤) ឬវិធាន ៥៧ នោះទេ ប៉ុន្តែ និយមន័យនេះយោងយ៉ាងច្បាស់លាស់ទៅលើ "បុគ្គលណាម្នាក់*ដែលជាកម្មវត្ថុទៅនឹងការចោទប្រកាន់* នៅក្នុងរឿងក្តីជាក់លាក់ណាមួយ *ក្នុងចន្លោះពីពេលមានដីកាបញ្ជូនរឿងឱ្យស៊ើបសួរ* និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់"។ នៅក្នុងការសន្និដ្ឋានថាតើបុគ្គលម្នាក់មានលក្ខណៈសម្បត្តិជា "ជនត្រូវចោទ" ដែរឬអត់នោះ បញ្ហាចំពោះមុខគឺថាតើជននោះជា "កម្មវត្ថុទៅនឹងការចោទប្រកាន់" ដែរឬអត់ទៅវិញទេ"។ ជាក់ស្តែង បុគ្គលម្នាក់ដែលត្រូវបានចោទប្រកាន់ជាផ្លូវការដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងអំឡុងពេលចូលមកបង្ហាញខ្លួនជាលើកដំបូងគឺជា "កម្មវត្ថុទៅនឹងការចោទប្រកាន់ហើយ" ប៉ុន្តែ នេះមិនមែនជាបុរេលក្ខខណ្ឌនោះទេ។ អត្ថន័យនៃពាក្យថាជា "កម្មវត្ថុទៅនឹងការចោទប្រកាន់" មានលក្ខណៈទូលំ

[47] វិធានផ្ទៃក្នុងគ្រាន់តែបញ្ជាក់ថា ឋានៈរបស់ "ជនសង្ស័យ" ត្រូវបញ្ចប់ នៅពេលដែលជននោះត្រូវបាន "ចោទប្រកាន់" ហើយ ឋានៈរបស់ "ជនត្រូវចោទ" ចាប់ផ្តើម នៅពេលដែលជននោះក្លាយជា "កម្មវត្ថុនៃការចោទប្រកាន់"។ កាលៈទេសៈទាំងពីរនេះមិនត្រូវជាប់ទាក់ទងគ្នាជាចាំបាច់នោះទេ ជាពិសេស ប្រសិនបើជនណាម្នាក់មានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចដែលបានបញ្ជាក់កាន់តែលម្អិតខាងក្រោម។

ទូលាយជាងនេះទៅទៀត។ និយមន័យនេះសំដៅទៅលើជនណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ[48]។

18. នៅ អ.វ.ត.ក[49] ការទទួលខុសត្រូវចោទប្រកាន់ ឬផ្តួចផ្តើមបណ្តឹងអាជ្ញា ត្រូវបានប្រគល់សិទ្ធិអំណាចទៅឱ្យសហព្រះរាជអាជ្ញា ដែលស្រដៀងគ្នាទៅនឹងច្បាប់កម្ពុជាដែរ[50]។ បើនិយាយតាមផ្លូវគតិយុត្តិ សហព្រះរាជអាជ្ញាផ្តួចផ្តើមបណ្តឹងអាជ្ញា ដោយការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ "ប្រឆាំងនឹងបុគ្គលមួយ ឬ ច្រើនរូប ឬប្រឆាំងនឹងអញ្ញាតជន" ដែលនាំឱ្យឈានដល់ការបើកកិច្ចស៊ើបសួរជាស្វ័យប្រវត្តិចំពោះឧក្រិដ្ឋកម្មដែលសហព្រះរាជអាជ្ញាចោទប្រកាន់ថា ជនសង្ស័យដែលគេស្គាល់ឈ្មោះ ប្រសិនបើមាន អាចទទួលខុសត្រូវចំពោះបទល្មើសនោះ[51]។ ចំពោះបុគ្គល

---

[48] *សូមមើល* Bryan A. Garner (ed.) វចនានុក្រម *Black's Law Dictionary* បោះពុម្ពលើកទី ៨ ឆ្នាំ ២00៤ និយមន័យនៃ "ការចោទប្រកាន់" គឺ ("ផ្តួចផ្តើម និងបន្តធ្វើការចោទប្រកាន់មកលើបុគ្គលណាម្នាក់")។

[49] *សូមមើល* កិច្ចព្រមព្រៀង មាត្រា ៦(១) ដែលចែងថា៖ ("មានព្រះរាជអាជ្ញាខ្មែរមួយរូប និងព្រះរាជអាជ្ញាអន្តរជាតិមួយរូប ដែលមានសមត្ថកិច្ចបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះក្តីទាំងពីរថ្នាក់ ដោយបម្រើការជាសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាទទួលខុសត្រូវលើ *ការងារចោទប្រកាន់* ")។ មាត្រា ១៦ នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា៖ "រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញាពីរនាក់" *និងមាត្រា ២០ ថ្មី* ចែងថា៖ ("សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន")។

[50] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២ ដែលចែងថា៖ ("បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអាទិភាពនៃបទល្មើស បង្ហាញឱ្យឃើញនូវពិរុទ្ធភាពរបស់ជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់") *ហើយ* មាត្រា ៤ ចែងថា៖ ("បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។ អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ")។

[51] *សូមមើល* វិធាន ៥៣(១) នៃវិធានផ្ទៃក្នុងដែលចែងថា៖ ("ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកើតមានពិត សហព្រះរាជអាជ្ញា*ត្រូវបើកការស៊ើបសួរដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត*ប្រឆាំងនឹងបុគ្គលមួយ ឬ ច្រើនរូប ឬប្រឆាំងនឹងអញ្ញាតជន") *ហើយ*វិធាន ៥៥(១) ចែងថា៖ ("ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ *សូមមើលផងដែរ* នៅក្នុងច្បាប់កម្ពុជា មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា៖ ("ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម៖ - ការបើកធ្វើការស៊ើបសួរ -ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម")។ មាត្រា ៤៤ ចែងថា៖ ("ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ ការស៊ើបសួរត្រូវបានបើកឡើង តាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន")។ មាត្រា ១២៤ (ដែលចែងបន្ថែមទៅលើខ្លឹមសារនៃមាត្រា ៤៤ ចែងថា៖ "ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿង

ទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នេះជាកាលៈទេសៈដែលពួកគេត្រូវប្រឈមមុខនឹងការចោទប្រកាន់ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងនិយមន័យនៃពាក្យថាជនត្រូវចោទ ("នៅក្នុងអំឡុងពេលចន្លោះពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ(...)")។ តាមពិតទៅ វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា បុគ្គលដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អាចត្រូវបានចោទប្រកាន់ជាផ្លូវការដោយសហចៅក្រមស៊ើបអង្កេត ដោយមិនចាំបាច់ពិចារណាថាតើមាន "តម្រុយច្បាស់លាស់ និងស៊ីចង្វាក់គ្នា" ថាបុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែរឬអត់នោះទេ ហើយការអនុវត្តបែបនេះមិនធ្វើឡើងចំពោះបុគ្គលទាំងឡាយដែលមិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ[52]។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងចែងបន្ថែមទៀតថា ជនទាំងនោះ "មានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារ (...) និងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប")[53]។ ដោយសារពួកគេជា "កម្មវត្ថុទៅនឹងការចោទប្រកាន់" បុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺស្ថិតនៅក្នុងវង្វង់វិសាលភាពនៃនិយមន័យ "ជនត្រូវចោទ" ដោយស្វ័យប្រវត្តិ ដូចបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុង បើសិនជាមិន និងរហូតទាល់តែសហចៅក្រមស៊ើបអង្កេតសម្រេចថា ពួកគេលែងជាជនត្រូវចោទតទៅទៀតហើយ។ ផ្ទុយទៅនឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុងមិនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតទាំងពីររូប ធ្វើការសម្រេចថាតើមានភស្តុតាងគ្រប់គ្រាន់សម្រាប់បុគ្គលណាម្នាក់*ដែលមានឈ្មោះរួចមកហើយ* នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវចាត់ទុកថាជា "ជនត្រូវចោទ" នោះទេ ដោយហេតុថា លក្ខខណ្ឌតម្រូវនេះពាក់ព័ន្ធតែចំពោះអ្នក*ដែលមិនមានឈ្មោះ* ដូចដែលបានរម្លឹកខាងលើ[54]។ វិធាន ៥៧(១) នៃវិធានផ្ទៃក្នុង ក៏មិនបានតម្រូវថា ការចូល

---

ឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានទេ")។

[52] វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង៖ សហចៅក្រមស៊ើបអង្កេត មិនអាចបើកការចោទប្រកាន់ប្រឆាំងនឹងបុគ្គលណាម្នាក់ដែលមិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយមិនបានសួរយោបល់ពីសហព្រះរាជអាជ្ញាជាមុនបានទេ។

[53] វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងផ្តល់សិទ្ធិទាំងនេះដល់ "ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់" ដែលចាំបាច់រួមមាន ជនទាំងឡាយណាដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

[54] លក្ខខណ្ឌដូចគ្នានេះមានចែងយ៉ាងពិតប្រាកដនៅក្នុងច្បាប់កម្ពុជា។ *សូមមើល* មាត្រា ១២៦(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មកបង្ហាញខ្លួនជាលើកដំបូង គឺជាបុរេលក្ខខណ្ឌដើម្បីចាត់ទុកថាជា "ជនត្រូវចោទ" នោះទេ។ ផ្ទុយទៅវិញ វិធាននេះគ្រាន់តែចែងថា "នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់*ជនត្រូវចោទ*នោះ [មិនមែន "ជនសង្ស័យ" ទេ] និងប្រាប់ជននោះអំពីបទចោទប្រកាន់ (...)" វិធាននេះបញ្ជាក់ថា បុគ្គលណាម្នាក់មានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានចាត់ទុកបែបនេះរួចទៅហើយ[55]។

19. ទីពីរ យើងយល់ឃើញថា ការពិនិត្យឱ្យបានច្បាស់លាស់ទៅលើសិទ្ធិដែលត្រូវបានភ្ជាប់ទៅនឹងឋានៈរបស់ "ជនត្រូវចោទ" តម្រូវឱ្យមានការផ្តល់អាទិភាពទៅលើឃ្លាថា "កម្មវត្ថុទៅនឹងការចោទប្រកាន់" ខ្ពស់ជាងដំណើរការចោទប្រកាន់ជាផ្លូវការ ដើម្បីធានាដល់ការគោរពគោលការណ៍ជាមូលដ្ឋានដែលគ្របដណ្តប់ទៅលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដូចមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង។ ជាពិសេស គោលការណ៍ជាមូលដ្ឋានទាំងនេះធានាដល់ផលប្រយោជន៍របស់ជនសង្ស័យ និងជនត្រូវចោទ[56] ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព[57] និងដើម្បីធានាថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក មានយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ ហើយរក្សាឱ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ[58] និងដើម្បីធានាថា ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ មានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងសិទ្ធិមានមេធាវីការពារតាមជម្រើសរបស់ខ្លួន[59]។

20. របបគតិយុត្តិដែលអនុវត្តនៅ អ.វ.ត.ក ចែងថា បន្ទាប់ពីសហព្រះរាជអាជ្ញាបញ្ជូនដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមក សហចៅក្រមស៊ើបអង្កេតត្រូវបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[60] ដែលនៅទីបំផុត អាចនាំឱ្យសហចៅក្រមស៊ើបអង្កេតលើកលែង

[55] លក្ខខណ្ឌដូចគ្នានេះមានចែងយ៉ាងពិតប្រាកដនៅក្នុងច្បាប់កម្ពុជា។ *សូមមើល* មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[56] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[57] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[58] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង។

[59] វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។

[60] វិធាន ៥៥(១) និង (៥) នៃវិធានផ្ទៃក្នុង។

ការចោទប្រកាន់ ឬចេញដីកាដំណោះស្រាយបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ[61]។ នៅពេលដែលដីកាដំណោះស្រាយត្រូវបានចេញរួចរាល់ហើយ ត្រូវបញ្ជូនសំណុំរឿងដែលមានភស្តុតាងទាំងអស់ដែលប្រមូលបាននៅក្នុងអំឡុងពេលស៊ើបសួរ ទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីបង្កើតបានជាមូលដ្ឋានសម្រាប់ការជំនុំជម្រះ[62] ដោយសារថា ភាគីទាំងអស់មិនត្រូវបានអនុញ្ញាតឱ្យស៊ើបអង្កេតដោយខ្លួនឯងបានទេ។ កិច្ចស៊ើបសួរត្រូវដឹកនាំដោយសហចៅក្រមស៊ើបអង្កេត ប៉ុន្តែ តាមរយៈនេះ ភាគីទាំងអស់ត្រូវបានអនុញ្ញាតឱ្យចូលរួមយ៉ាងសកម្ម ដោយ៖ ១) ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត "ចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ[63] ២) ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត "សួរចម្លើយ[ខ្លួន] ស្តាប់ចម្លើយសាក្សី ចុះទៅដល់កន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្តុតាងដទៃទៀត ក្នុងនាមឱ្យ[ពួកគេ][64] ៣) ប្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេតដែលជាកម្មវត្ថុនៃការពិនិត្យពិច័យតាមផ្លូវឧទ្ធរណ៍ ឬជំទាស់ទៅនឹងបណ្តឹងឧទ្ធរណ៍ដែលប្តឹងដោយភាគីដទៃទៀត[65] ៤) ស្នើសុំឱ្យធ្វើមោឃភាពទៅលើកិច្ចស៊ើបសួរ ដែលត្រូវរងការប៉ះពាល់ដោយសារកំហុសនីតិវិធី[66]។ ដើម្បីឱ្យមានប្រសិទ្ធភាពពេញលេញ សិទ្ធិទាំងនេះគួរត្រូវបានផ្តល់ឱ្យភាគីទាំងអស់នៅក្នុងឱកាសដំបូងបំផុត ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ស្របច្បាប់ណាមួយឡើយ។ តាមពិតទៅ វិធានផ្ទៃក្នុងចែងថា សិទ្ធិទាំងនេះត្រូវបានផ្តល់ជូនសហព្រះរាជអាជ្ញាតាំងពីពេលចាប់ផ្តើមកិច្ចស៊ើបសួរ និងជូនអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីពេលដែលពួកគេដាក់ពាក្យសុំឱ្យទទួលស្គាល់ខ្លួនជាជាដើមបណ្តឹងរដ្ឋប្បវេណីមកម្ល៉េះ[67]។ វិធានផ្ទៃក្នុងចែងបន្ថែមទៀតថា គេអាចត្រូវអនុវត្តសិទ្ធិ "ពេលណាមួយក្នុងអំឡុងកិច្ចស៊ើបសួរ"[68] តាមការអានវិធានផ្ទៃក្នុង មានលក្ខខណ្ឌតម្រូវថា ប្រហាក់ប្រហែលគ្នាទៅឱ្យភាគីដទៃទៀត បុគ្គលដែលអាច

[61] វិធាន ៦៧ នៃវិធានផ្ទៃក្នុង។

[62] វិធាន ៦៩ នៃវិធានផ្ទៃក្នុង។

[63] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

[64] វិធាន ៥៨(៦) និង ៥៩(៥) នៃវិធានផ្ទៃក្នុង។

[65] វិធាន ៧៤ នៃវិធានផ្ទៃក្នុង។

[66] វិធាន ៧៦ បកស្រាយផ្សំជាមួយនឹងនិយមន័យនៃពាក្យថា "ភាគីទាំងឡាយ" មានចែងក្នុងសទ្ទានុក្រម។

[67] *សូមមើល* វិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុង។

[68] *សូមមើល* វិធាន ៥៥(១០) ៥៨(៦) និង៥៩(៥) នៃវិធានផ្ទៃក្នុង។

ប្រឈមមុខនឹងការចោទប្រកាន់ ដោយសារពួកគេជាកម្មវត្ថុនៃការចោទប្រកាន់នោះ ពួកគេត្រូវបានផ្តល់ឱកាសឲ្យចូលរួមក្នុងកិច្ចស៊ើបសួរឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

21. បុគ្គលដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ប្រឈមមុខទៅនឹងការចោទប្រកាន់នៅទីបំផុត។ ពួកគេជាកម្មវត្ថុនៃការចោទប្រកាន់ជាក់លាក់ដោយសហព្រះរាជអាជ្ញាដែលថា ពួកគេអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ។ ការចោទប្រកាន់បន្ថែមទៀតអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ក៏អាចត្រូវបានធ្វើឡើងតាមរយៈពាក្យបណ្តឹងរបស់ជនរងគ្រោះ ឬពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ គោលការណ៍ស្តីពីសមភាពនៃគូក្តី ដែលមានចែងនៅក្នុងមាត្រា ១៤(៣) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយត្រូវបានយកមកចែងឡើងវិញនៅក្នុងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង តម្រូវថា ពួកគេត្រូវទទួលបានឱកាសសមហេតុផលដើម្បីការពាររឿងក្តីរបស់ខ្លួន នៅក្រោមលក្ខខណ្ឌដែលមិនធ្វើឲ្យពួក*គេមានការលំបាកខ្លាំង បើធៀបទៅនឹង* ភាគីដទៃទៀត[69]។ ត្រង់ចំណុចនេះ គណៈកម្មាធិការសិទ្ធិមនុស្សបានលើកឡើងថា សិទ្ធិខាងនីតិវិធីដូចគ្នានេះត្រូវផ្តល់ទៅឲ្យភាគីទាំងអស់ លើកលែងតែមានការបែងចែកភាពខុសគ្នាដោយផ្អែកទៅលើច្បាប់ និងអាចត្រូវបានធ្វើយុត្តិកម្មដោយផ្អែកទៅលើសំអាងហេតុជាសត្យានុម័ត និងសមហេតុផល ដែលមិនត្រូវធ្វើឲ្យមានការលំបាកជាក់ស្តែង ឬមានភាពមិនយុត្តិធម៌ចំពោះចុងចោទនោះឡើយ[70]។ តុលាការសិទ្ធិមនុស្សអឺរ៉ុប ក៏បានសង្កត់ធ្ងន់ទៅលើតម្រូវ

---

[69] *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប, *រឿងក្តីរវាង* *Abdulgadirov* *តទល់នឹង* *Azerbaijan*, សំណុំរឿងលេខ ២៤៥១០/០៦ សាលក្រម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ *និង* គណៈកម្មាធិការសិទ្ធិមនុស្ស, អត្ថបទអត្ថាធិប្បាយរួម លេខ ៣២ [៩០] ១៣, CCPR/C/GC/32 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ("អត្ថបទអត្ថាធិប្បាយរួម លេខ ៣២"), កថាខណ្ឌ ១៣។

[70] គណៈកម្មាធិការសិទ្ធិមនុស្ស, អត្ថបទអត្ថាធិប្បាយរួម លេខ ៣២, កថាខណ្ឌ ១៣ និង *រឿងក្តីរវាង* Dudko *តទល់នឹង ប្រទេសអូស្ត្រាលី* សំណុំរឿងលេខ ១៣៤៧/២០០៥ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ៧.៤ ("រដ្ឋជាភាគីត្រូវបង្ហាញថា វិសមភាពរវាងផ្នែកនីតិវិធីណាមួយ ត្រូវផ្អែកទៅលើសំអាងហេតុសមហេតុផល និងជាសត្យានុម័ត ដោយមិនធ្វើឲ្យមានការខូចប្រយោជន៍ជាក់ស្តែង ឬភាពអយុត្តិធម៌ដទៃទៀតចំពោះអ្នកនិពន្ធឡើយ)។ ដូចគ្នានេះដែរ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានយល់ឃើញទាក់ទងទៅនឹងបញ្ហានេះថា វិសមភាពចម្បងដែលមិនប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីទាំងមូល មិនរំលោភទៅលើមាត្រា ៦ នៃកតិកាសញ្ញានេះទេ។ *សូមមើល ផងដែរ* តុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តីរវាង* *Verdu Verdu* *តទល់នឹង ប្រទេសអេស្ប៉ាញ* សំណុំរឿងលេខ ៤៣៤៣២/០២ សាលក្រម ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ២៣-២៩ (ដែលតុលាការយល់ឃើញថា ដោយការខកខានមិនបានប្រាស្រ័យទាក់ទងជាមួយនឹងចុងចោទ នោះសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំចូលរួមជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា មិនមានឥទ្ធិពលទៅលើលទ្ធផលនៃកិច្ចដំណើរការនីតិវិធីនោះទេ ហើយហេតុដូច្នេះ មិនប៉ះពាល់ដល់សិទ្ធិរបស់គាត់នោះទេ)។ *សូមមើល ផងដែរ* អត្ថបទរបស់ Dovydas Vitkauskas និង

ការក្នុងការគិតគូរទៅដល់រូបភាព ក៏ដូចជាការយកចិត្តទុកដាក់ច្រើនចំពោះដំណើរការត្រឹមត្រូវនៃការស្វែងរកយុត្តិធម៌[71]។ នៅក្នុងបរិបទរបស់ អ.វ.ត.ក ភាពខុសគ្នានៃពេលវេលាសម្រាប់ចូលរួមនៅក្នុងកិច្ចស៊ើបសួរ និងសិទ្ធិចូលមើលសំណុំរឿង រវាងសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងជនសង្ស័យ អាចមានយុត្តិកម្មតាមផ្លូវច្បាប់ដោយផ្អែកលើឋានៈខុសៗគ្នារបស់ពួកគេ និងអាចបម្រើផលប្រយោជន៍ស្របច្បាប់ ជាពិសេស ដើម្បីការពារសច្ចភាពនៃកិច្ចស៊ើបសួរ។ ប៉ុន្តែ ស្ថានភាពនេះអាចបណ្តាលឱ្យមានអតុល្យភាពពិតប្រាកដ ឬតាមការយល់ឃើញ រវាងលទ្ធភាពរបស់ភាគីក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន ដែលអាចមានលំបាកក្នុងការជួសជុល ឬទូទាត់សងតាមរយៈការការពារតាមផ្លូវនីតិវិធី។ នៅពេលដែលបុគ្គលទាំងឡាយត្រូវបានកំណត់គោលដៅជាក់លាក់ដោយសហព្រះរាជអាជ្ញា ហើយដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់លទ្ធភាព ឱ្យមានឥទ្ធិពលមកលើលទ្ធផលនៃកិច្ចស៊ើបសួរ តាមរយៈ *ក្នុងចំណោមនោះ* សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ និងដើម្បីធ្វើការទាមទារសំណងផ្លូវចិត្ត និងសម្ងូហភាពរបស់ខ្លួន[72] នោះ បុគ្គលទាំងនេះគួរត្រូវបានផ្តល់ឱកាសឱ្យបានដឹងពីបទចោទប្រកាន់ប្រឆាំងនឹងពួកគេ តទល់នឹងបទចោទទាំងនេះ និងមានឥទ្ធិពលទៅលើកិច្ចស៊ើបសួរក្នុងរបៀបដូចគ្នានឹងភាគីដទៃទៀតដែរ។ ហេតុដូច្នេះ ដោយសារតែពួកគេជា "កម្មវត្ថុនៃការចោទប្រកាន់" នោះបុគ្គលដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវតែទទួលបានសិទ្ធិដែលភ្ជាប់ទៅនឹងឋានៈរបស់ជនត្រូវចោទ ដោយមិនគិតថា ពួកគេមិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការពីសំណាក់សហចៅក្រមស៊ើបអង្កេត និងមិនទាន់ត្រូវបានកោះហៅឱ្យចូលមកបង្ហាញខ្លួនជាលើកដំបូងនោះទេ។

22. ការបកស្រាយនេះ ឆ្លុះបញ្ចាំងពីវិធានដែលត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធយុត្តាធិការច្បាប់ស៊ីវិលឡូ (civil law) ក្នុងស្រុកមួយចំនួន។ ក្នុងប្រព័ន្ធនេះ បុគ្គលដែលទំនងជាអាចត្រូវបានចោទប្រកាន់

---

Grigoriy Dikov "ការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលស្ថិតនៅក្រោមអនុសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស" ក្រុមប្រឹក្សាទ្វីបអឺរ៉ុប, ទីក្រុង Strasbourg, ឆ្នាំ ២០១២ ទំព័រ ៤៨ (ដែលបញ្ជាក់ថា ទោះជាមិនមាននិយមន័យទូលំទូលាយថាតើអ្វីដែលជាលក្ខខណ្ឌអប្បបរមានៃ "សមភាពរវាងគូក្តី" ត្រូវមានការធានាផ្នែកនីតិវិធីឱ្យបានគ្រប់គ្រាន់ ដែលសមស្របទៅនឹងលក្ខណៈនៃរឿងក្តី និងឆ្លើយតបទៅនឹងអ្វីដែលមាននៅចំពោះមុខរវាងភាគីទាំងឡាយ)។

[71] តុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តីរវាង Bulut តទល់នឹង ប្រទេសអូទ្រីស* សំណុំរឿងលេខ ១៧៣៥៨/៩០ សាលក្រម ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ កថាខណ្ឌ ៤៧។

[72] *សូមមើល* វិធាន ២៣ នៃវិធានផ្ទៃក្នុង។

បញ្ជូនទៅជំនុំជម្រះ ដោយហេតុថាពួកគេមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬបើមិនដូច្នោះទេ ត្រូវបានសង្ស័យថាទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ដោយស្ថាប័នអយ្យការ ឬដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិចូលរួមនៅក្នុងកិច្ចស៊ើបសួររបស់តុលាការ ហើយមេធាវីរបស់ពួកគេមានសិទ្ធិពិនិត្យសំណុំរឿង ប៉ុន្តែអាចមានលក្ខខណ្ឌកំហិត ឬការកំណត់ដែលអាចមាន ដែលនឹងត្រូវយកមកពិភាក្សាខាងក្រោម។ ឧទាហរណ៍ តាមក្រមនីតិវិធីព្រហ្មទណ្ឌបារាំងជាធរមានបច្ចុប្បន្ន[73] ជនសង្ស័យណាម្នាក់ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទោះបីជាលែងត្រូវបានចាត់ទុកដោយស្វ័យប្រវត្តិទៀតថាជា "ជនត្រូវចោទ" ហើយក៏ដោយ ក៏ជនសង្ស័យរូបនេះគឺជា "សាក្សីជំនួយ"[74]។ សាក្សីជំនួយ បើទោះជាមិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីរហូតទាល់តែត្រូវបាន "ចោទប្រកាន់" ដោយចៅក្រមស៊ើបសួរក៏ដោយ[75] ក៏សាក្សីនេះមានសិទ្ធិចូលរួមនៅក្នុងកិច្ចស៊ើបសួររបស់តុលាការ[76] និងមានសិទ្ធិមានមេធាវីតំណាង

---

[73] គេកត់សម្គាល់ឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងបានឆ្លងកាត់ការកែទម្រង់ស៊ីជម្រៅមួយនៅក្នុងឆ្នាំ ២០០០ ដើម្បីទប់ស្កាត់ផលវិបាកសង្គមដ៏គ្រោះថ្នាក់សម្រាប់បុគ្គលដោយសារតែការចោទប្រកាន់ (ការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) និងភាពចាំបាច់ក្នុងការពង្រឹងសច្ចធារណ៍និរទោស។ ការធ្វើកំណែទម្រង់នេះមានគោលបំណងពន្យារពេលដែលបុគ្គលម្នាក់ត្រូវបានចោទប្រកាន់ ឬ ដើម្បីជៀសវាការចោទប្រកាន់ ដោយរក្សាលទ្ធភាពសម្រាប់ចៅក្រមស៊ើបអង្កេតក្នុងការសួរចម្លើយជនសង្ស័យ និងក្នុងគោលបំណងផ្តល់សិទ្ធិចាំបាច់ដល់ជនសង្ស័យ។ *សូមមើល* Christian Guéry, « Instruction préparatoire », *Répertoire de droit pénal et de procédure pénale Dalloz* ចុះខែ មករា ឆ្នាំ ២០០៨ (ធ្វើបច្ចុប្បន្នភាពចុងក្រោយនាខែ មីនា ឆ្នាំ ២០១៣) កថាខណ្ឌ ៣១២ និង ៣៥៩។ ទោះបីជាបុគ្គលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពុំត្រូវបានចាត់ទុកថាជាជនត្រូវចោទតាមរយៈអង្គហេតុនេះក៏ដោយ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងបានបង្កើតឋានៈ "សាក្សីជំនួយ" ដែលសិទ្ធិមួយចំនួនត្រូវបានផ្តល់ឱ្យសាក្សីជំនួយនេះ។ យើងកត់សម្គាល់ឃើញថា បទប្បញ្ញត្តិបច្ចុប្បន្ននៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងខុសពីវិធានផ្ទៃក្នុង អ.វ.ត.ក និងច្បាប់កម្ពុជា។ ការយោងទៅប្រព័ន្ធនេះបានធ្វើឡើង ដើម្បីជាផ្នែកមួយនៃការវិភាគដោយប្រៀបធៀបលើសិទ្ធិចូលរួមនៅក្នុងកិច្ចស៊ើបសួរ និងសិទ្ធិពិនិត្យមើលសំណុំរឿងនៅក្នុងប្រព័ន្ធគតិយុត្តិខុសៗគ្នា។

[74] មាត្រា ១១៣-១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[75] *សូមមើល ឧ.* Cass. Crim. ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ពុំមានការបោះពុម្ពផ្សាយ pourvoi n° 01-83.529។ Cass. Crim. ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ព្រឹត្តប័ត្រព្រហ្មទណ្ឌ ឆ្នាំ ២០១២ លេខ ៤៥។

[76] សាក្សីជំនួយត្រូវបានផ្តល់សិទ្ធិជាក់លាក់ i) សិទ្ធិស្នើសុំឱ្យតទល់ជាមួយនឹងបុគ្គលដែលចោទប្រកាន់ ឬ ថ្កោលទោសខ្លួន (មាត្រា ១១៣-៣) ii) សិទ្ធិសួរសំណួរ ឬបង្ហាញការសង្កេតសង្ខេបតាមរយៈមេធាវីរបស់ខ្លួននៅក្នុងពេលសួរចម្លើយ និងសួរតទល់គ្នា (មាត្រា ១២០) iii) សិទ្ធិស្នើសុំមោឃភាពកិច្ចស៊ើបសួរ (មាត្រា ១១៣-៣) iv) សិទ្ធិទទួលបានការជូនដំណឹងអំពីរបាយការណ៍កោសលវិច័យ និងសិទ្ធិស្នើសុំបដិកោសលវិច័យ (មាត្រា ១៦៧) v) សិទ្ធិស្នើសុំបិទកិច្ចស៊ើបសួរ (មាត្រា ១៧៥-១) និងសិទ្ធិស្នើសុំដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យនៅក្នុងដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធី (មាត្រា ១១៣-៦)។

ដែរ។ មេធាវីរបស់សាក្សីជំនួយទទួលបានសិទ្ធិពិនិត្យសំណុំរឿងស៊ើបអង្កេត *យ៉ាងយូរបំផុត* បួនថ្ងៃមុនការស្តាប់ចម្លើយលើកទីមួយដោយចៅក្រមស៊ើបអង្កេត[77]។ នៅក្នុងប្រទេសអាល្លឺម៉ង់ *ជនសង្ស័យ* ត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងកិច្ចស៊ើបសួរ[78] ហើយជាគោលការណ៍ មេធាវីរបស់ពួកគេក៏មានសិទ្ធិពិនិត្យសំណុំរឿងចាប់តាំងពីពេលកិច្ចស៊ើបសួរដំបូងមកម្លេះ (ដោយរដ្ឋអាជ្ញា ឬ ចៅក្រមស៊ើបអង្កេត ទៅតាមករណីសមស្រប) ហើយយ៉ាងយូរបំផុត នៅមុនពេលស្តាប់ចម្លើយលើកទីមួយ[79]។ ចំណែកនៅក្នុងប្រទេសកូសូវ៉ូវិញ "ជនណាដែលរដ្ឋអាជ្ញាមានមន្ទិលសង្ស័យដោយសមហេតុផលថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ" ត្រូវដាក់បញ្ចូលឈ្មោះនៅក្នុងសេចក្តីសម្រេចផ្តួចផ្តើមកិច្ចស៊ើបសួរ ហើយត្រូវមានសិទ្ធិដូចគ្នាទាំងអស់ទៅនឹងសិទ្ធិរបស់ជនជាប់ចោទដោយស្វ័យប្រវត្តិ រួមទាំងសិទ្ធិចូលរួមនៅក្នុងកិច្ចស៊ើបសួរផងដែរ[80]។ ជនជាប់ចោទ ឬ មេធាវីរបស់ពួកគេ មានសិទ្ធិពិនិត្យសំណុំរឿងចាប់តាំងពីពេលស៊ើបសួរដំបូងមកម្លេះ[81]។

23. យោងតាមហេតុផលខាងលើនេះ យើងយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសផ្នែកអង្គច្បាប់ចំពោះការយល់ឃើញរបស់លោកលើពាក្យ "ជនត្រូវចោទ"។ ជនណាម្នាក់ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរគឺជា "ជនត្រូវចោទ" តាំងពីពេលដែល

---

[77] *សូមមើល* មាត្រា ១១៣-៣ និងមាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[78] *សូមមើល* Michael Bohlander *គោលការណ៍នៃនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់* គ្រឹះស្ថានបោះពុម្ពផ្សាយ Hart ឆ្នាំ ២០១២ ("Bohlander") ("អ្វីដែលបានកើតឡើងនៅក្នុងពេលជំនុំជម្រះនឹងត្រូវកំណត់ក្នុងកម្រិតជាច្រើន - ហើយស្ទើរតែមិនអាចកែទៅវិញ - ទៅក្នុងដំណាក់កាលមុនការជំនុំជម្រះ - ដោយនគរបាលយុត្តិធម៌ ស្ថាប័នអយ្យការ និងចៅក្រមស៊ើបសួរនៅមុនដំណាក់កាលជំនុំជម្រះ និង ពេលខ្លះ ដោយមេធាវីការពារក្តី។ [...] ដូច្នេះ *អ្នកដែលអាចជាជនជាប់ចោទ* ត្រូវមានផលប្រយោជន៍នៅក្នុងការការពារដ៏ប្រសើរបំផុតមួយ និងនៅក្នុងមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតមួយ ដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងខ្លួនតាំងពីពេលចាប់ផ្តើមដំបូងនៅពេលដែលខ្លួននៅជាជនសង្ស័យនៅឡើយ")។

[79] *សូមមើល* ផ្នែក ១៤៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ ដោយអានរួមជាមួយនឹងផ្នែក ១៣៧ *និង*ផ្នែក ១៦៣ក និង ១៣៦។ *សូមមើលផងដែរ* Bohlander ទំព័រ ៦៨។

[80] *សូមមើល* មាត្រា ១០៣(៣) និងមាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកូសូវ៉ូ។ *សូមមើលផងដែរ* មាត្រា ៩ មាត្រា ២១៦(១) និង ១៤១។

[81] មាត្រា ២១៣(២) និងមាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកូសូវ៉ូចែងច្បាស់ថា "តាមគំនិតផ្តួចផ្តើមនៅក្នុងដំណាក់កាលស៊ើបអង្កេត រដ្ឋអាជ្ញាមានកាតព្វកិច្ចជាវិជ្ជមានក្នុងការផ្តល់សិទ្ធិពិនិត្យមើលសំណុំរឿងដល់បុគ្គលណាដែលមានឈ្មោះជាចុងចោទ ឬ ដល់មេធាវីការពារក្តីរបស់ពួកគេ"។ ក៏ប៉ុន្តែ សិទ្ធិនេះអាចស្ថិតនៅក្រោមការដាក់កំហិត ដែលនឹងត្រូវយកមកពិភាក្សានាពេលក្រោយ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបានដាក់ទៅចៅក្រមស៊ើបអង្កេត លើកលែងតែចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីសម្រេចមួយថា ជននេះលែងជាកម្មវត្ថុនៃការចោទប្រកាន់ទៀតហើយ។

24. នៅក្នុងរឿងក្ដីបច្ចុប្បន្ន [redacted] ត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិបញ្ចូលឈ្មោះជាជនដែលអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[82]។ ចាប់តាំងពីពេលដែលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបានដាក់ទៅចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០៩ ដើម្បីបើកកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៤, [redacted] ត្រូវបាន "ស្ថិតនៅក្រោមកម្មវត្ថុនៃការចោទប្រកាន់"។ យើងកត់សម្គាល់ឃើញថា ទោះបីជាការស៊ើបអង្កេតបានចាប់ផ្ដើមតាំងពីជាងបួនឆ្នាំមុនក៏ដោយ គ្មានសេចក្ដីសម្រេចណាមួយត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងការដាក់បទចោទជាផ្លូវការ និងនាំ [redacted] មកបង្ហាញខ្លួនជាលើកដំបូងអនុលោមតាមវិធាន ៥៥(៤) និងវិធាន ៥៧ នៃវិធានផ្ទៃក្នុង ឬលើកលែងការចោទប្រកាន់ដាក់បន្ទុក [redacted] អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុងនោះទេ។ ទោះបីជាការពន្យារពេលនេះមានភាពខុសប្រក្រតីក៏ដោយ បើពិនិត្យទៅលើទម្លាប់អនុវត្តនាពេលមុនដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងជាទូទៅ បើពិនិត្យទៅលើយុត្តាធិការច្បាប់ស៊ីវិលឡូក៏ដោយ ក៏យើងពុំឃើញមានការចង្អុលបង្ហាញណាមួយថា [redacted] លែង "ជាកម្មវត្ថុនៃការចោទប្រកាន់" ទៀតហើយ។ ផ្ទុយមកវិញ ការពន្យារពេលដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងការធ្វើចំណាត់ការជាផ្លូវការអនុលោមតាមវិធាន ៥៧ ឬ វិធាន ៦៧ នៃវិធានផ្ទៃក្នុង ទំនងជាកើតចេញពីផលវិបាកនៃលក្ខខណ្ឌអប្បបរមាដែលចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ ដើម្បីដាក់ចេញបទចោទអនុលោមតាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង។ ត្រង់ចំណុចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបច្ចុប្បន្នបានពន្យល់ថា [redacted] ពុំទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការនៅឡើយទេ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំទាន់ធ្វើការកំណត់ថាតើពិតជាមាន "ភស្តុតាងជាក់លាក់ *និង* ស៊ីសង្វាក់គ្នា" ដែលអាចឲ្យ [redacted] ទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងឡាយដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឬក៏យ៉ាងណានោះទេ[83]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជ្រើសរើសអនុវត្តបទដ្ឋានតែមួយ ដូចបទដ្ឋានដែលត្រូវបានចែង

[82] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥(១) និងកថាខណ្ឌ ៨២-៩០។

[83] សេចក្ដីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៤៧។

ជាក់លាក់នៅក្នុងវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង *ចំពោះបុគ្គលដែលពុំមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពោលគឺ* បុគ្គលដែលសហព្រះរាជអាជ្ញាពុំទាន់មានហេតុផលជឿជាក់យ៉ាងច្បាស់លាស់ថា ពួកគេអាចបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក។ ករណី [redacted] មិនមែនដូច្នេះឡើយ។ បទដ្ឋាននេះមានលក្ខណៈស្ទើរតែតឹងរ៉ឹងដូចលក្ខខណ្ឌតម្រូវសម្រាប់ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក[84] ហើយក៏ស្រដៀងនឹងលក្ខខណ្ឌតម្រូវសម្រាប់ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅចំពោះមុខសាលាក្ដីអន្តរជាតិ ឬសាលាក្ដីអន្តរជាតូបនីយកម្មផ្សេងទៀតផងដែរ[85]។ ហេតុដូច្នេះ វាអាចធ្វើឱ្យសេចក្ដីសម្រេចចោទប្រកាន់ជាផ្លូវការ

---

[84] លក្ខខណ្ឌអប្បបរមាសម្រាប់ការចោទប្រកាន់ត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដោយទាមទារនូវ "លទ្ធភាពនៃពិរុទ្ធភាព" ដោយផ្អែកលើ "សម្ភារៈភស្តុតាងនៅក្នុងសំណុំរឿងដែលមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ និងអាចគាំទ្រ ដើម្បីផ្ដល់តម្លៃជាភស្តុតាងក្នុងកម្រិតមួយ"។ *សូមមើល* សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 កថាខណ្ឌ ១៣២៣។

[85] នៅតុលាការ ICC *សូមមើល* រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Lubanga* ICC-01/04-01/06 សេចក្ដីសម្រេចតម្កល់បទចោទ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៨-៣៩ ("អាស្រ័យហេតុនេះ អង្គជំនុំជម្រះពិចារណាឃើញថា ដើម្បីឱ្យស្ថាប័នអយ្យការបំពេញបន្ទុកនៃភស្តុតាង ស្ថាប័ននេះត្រូវផ្ដល់ភស្តុតាងជាក់ស្ដែង និងរូបិយ ដើម្បីបង្ហាញព្រំដែនច្បាស់លាស់នៃសំអាងហេតុដែលបង្ហាញពីការចោទប្រកាន់ជាក់លាក់")។ *សូមមើល* ក្នុងអានុភាពដូចគ្នា រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង William Samoei Ruto និងជនដទៃទៀត* ICC-01/09-01/11 សេចក្ដីសម្រេចស្ដីពីការតម្កល់បទចោទ អនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៤០។ នៅសាលាក្ដី ICTY និងសាលាក្ដី ICTR *សូមមើល*វិធាន ៤៧(ខ) នៃវិធានភស្តុតាង និងនីតិវិធីនៃសាលាក្ដី ICTY និងសាលាក្ដី ICTR ("មានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្ដល់មូលដ្ឋានសមហេតុផលដើម្បីឱ្យយើងជឿជាក់ថា ជនសង្ស័យបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការនៃសាលាក្ដី")។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Milosevic និងជនដទៃទៀត* សេចក្ដីសម្រេចស្ដីពីការពិនិត្យមើលឡើងវិញលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងពាក្យសុំចេញដីកាសម្រេចកើតចេញពីការចោទប្រកាន់ផ្សេងទៀត អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៩។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Delalic និង Delic* IT-96-21-T សេចក្ដីសម្រេចលើញត្តិសម្រាប់ការដោះលែងបណ្ដោះអាសន្នដែលត្រូវបានដាក់ដោយជនជាប់ចោទ Zejnil Delalic អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃ ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦ កថាខណ្ឌ ២៣ ("ដើម្បីបង្កើតជាមូលដ្ឋានសមហេតុផល អង្គហេតុត្រូវតែជាអង្គហេតុដែលស្ថិតនៅក្នុងដៃរបស់រដ្ឋអាជ្ញាដែលលើកឡើងនូវភាពសង្ស័យច្បាស់លាស់មួយថា ជនសង្ស័យមានពិរុទ្ធភាពនៃឧក្រិដ្ឋកម្ម (...)។ ហេតុដូច្នេះ ភស្តុតាងពុំចាំបាច់ជាភស្តុតាងជាក់លាក់ ឬ គួរឱ្យជឿជាក់ជាចំហនោះទេ។ ភស្តុតាងនេះគួរត្រឹមគ្រប់គ្រាន់ ឬ សមស្របគ្រាន់តែអាចជឿជាក់ថា ជនសង្ស័យបានប្រព្រឹត្តឧក្រិដ្ឋកម្ម")។ រឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Ntakirutimana និងជនផ្សេងទៀត* ICTR-96-10-T សេចក្ដីសម្រេចស្ដីពីញត្តិបឋមដែលត្រូវបានដាក់ដោយមេធាវីការពារក្ដី និងដីកាសម្រេចច្រានចោល ១ ២ ៣ និង ៦ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃ ១៥ ខែ កក្កដា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៦ ("ពាក្យមូលដ្ឋានសមហេតុផលអាចត្រូវបកស្រាយថាជាអង្គហេតុ និងកាលៈទេសៈ ដែលអាចផ្ដល់យុត្តិកម្មលើបុគ្គលដ៏សមហេតុផលសាមញ្ញជឿជាក់ថា ជនស្ស័យបានប្រព្រឹត្តឧក្រិដ្ឋ

ធ្វើនៅក្នុងដំណាក់កាលស៊ើបអង្កេតចុងក្រោយណាមួយ[86]។ យើងកត់សម្គាល់ឃើញបន្ថែមទៀតថា អតីតចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានជូនដំណឹងដល់ [redacted] នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ អំពីឧក្រិដ្ឋកម្មដែល [redacted] ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវ "ដោយផ្អែកលើទាំងអង្គហេតុដូចបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា (sic) *និងអង្គហេតុរកឃើញរហូតមកដល់ពេលនេះក្នុងពេលស៊ើបអង្កេត*"[87]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបច្ចុប្បន្នមិនបានធ្វើការបង្ហាញណាមួយថា ការលើកឡើងនេះអាចពុំត្រឹមត្រូវទៀតទេដោយសារតែវឌ្ឍនភាពនៃការស៊ើបអង្កេត។ ហេតុដូច្នេះ យើងយល់ឃើញថា ដោយសារតែថា [redacted] ត្រូវបានដាក់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងពុំមានការបង្ហាញណាមួយថា [redacted] លែងជាកម្មវត្ថុនៃការចោទប្រកាន់ទៀតហើយនោះ ដូច្នេះ [redacted] គឺជា "ជនត្រូវចោទ" យោងតាមនិយមន័យនៃវិធានផ្ទៃក្នុង។

25. លើសពីនេះ យើងពិចារណាឃើញថា ការផ្ដល់ឱកាសឲ្យ [redacted] ចូលរួមនៅក្នុងការស៊ើបអង្កេត និងមានសិទ្ធិពិនិត្យសំណុំរឿង ក្រោមលក្ខខណ្ឌកំណត់ដែលអាចមាន គឺជាការចាំបាច់នៅក្នុងដំណាក់កាលនេះ ដើម្បីការពារសិទ្ធិជាសារវន្តរបស់គាត់ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ផ្ទុយពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ យើងយល់ឃើញថា [redacted] ក៏ជាកម្មវត្ថុនៃ "បទចោទព្រហ្មទណ្ឌ" យោងតាមនិយមន័យនៃច្បាប់ស្ដីពីសិទ្ធិមនុស្ស ហេតុដូច្នេះ គាត់មានសិទ្ធិទទួលបានការការពារអនុលោមតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។ យើងត្រូវនឹកឃើញថា ច្បាប់សិទ្ធិមនុស្ស "ចង់បាន "សារធាតុ" ជាជាងការចាប់ផ្ដើម "បទចោទ" "ជាផ្លូវការ" [ហើយ] ច្បាប់នេះតម្រូវឲ្យតុលាការពិនិត្យមើលហួសពីលក្ខណៈខាងក្រៅ និងត្រូវពិនិត្យតថភាពជាក់ស្ដែងនៃនីតិវិធី ដើម្បីកំណត់ថាតើពិតជាមាន

---

កម្ម។ ត្រូវមានអង្គហេតុដែលលើកឡើងអំពីភាពសង្ស័យច្បាស់លាស់ថា ជនសង្ស័យមានពិរុទ្ធភាពនៃការប្រព្រឹត្តបទល្មើស ដើម្បីឲ្យមូលដ្ឋានសមហេតុផលមានអត្ថិភាព")។

[86] ដើម្បីជាការប្រៀបធៀប គេកត់សម្គាល់ឃើញថា បទដ្ឋានសម្រាប់ការចោទប្រកាន់ដែលត្រូវបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់មានលក្ខណៈតឹងរ៉ឹងជាងបទដ្ឋាន ដែលត្រូវបានអនុវត្តក្នុងពេលបច្ចុប្បន្ននៅក្នុងប្រព័ន្ធបារាំង ដែលបុគ្គលម្នាក់អាចត្រូវបានចោទប្រកាន់នៅពេលមានភស្តុតាង*ច្បាស់លាស់ ឬ ស៊ីសង្វាក់* បង្ហាញថា បុគ្គលណាម្នាក់អាចបានប្រព្រឹត្តឧក្រិដ្ឋកម្ម។ *សូមមើល* មាត្រា ៨០-១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[87] ការជូនដំណឹងចុះថ្ងៃទី ២៩ ខែ កុម្ភៈ កថាខណ្ឌ។

"បទចោទ" ដែរឬអត់"[88]។ ដូចបានលើកឡើងដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប "ទោះបីជា "បទចោទ" *យោងតាមគោលបំណងនៃមាត្រា ៦ § ១ (មាត្រា ៦-១)* [ដូចគ្នានឹងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ] ជាទូទៅ អាចកំណត់និយមន័យថាជា "ការជូនដំណឹងជាផ្លូវការដល់ជនណាម្នាក់ដោយអាជ្ញាធរមានសមត្ថកិច្ចអំពីការចោទប្រកាន់ថា ជននេះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ" ក៏ដោយ ក៏នៅក្នុងករណីខ្លះ វាអាចមានទម្រង់ជាវិធានការផ្សេងទៀត ដែលមានឥទ្ធិពលដោយសារតែការចោទប្រកាន់បែបនេះ ហើយ ដូចគ្នាដែរប៉ះពាល់យ៉ាងខ្លាំងលើស្ថានភាពរបស់ជនសង្ស័យ"[89]។ ត្រង់ចំណុចនេះ យើងកត់សម្គាល់ឃើញថា យោងតាមយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប "ជនណាម្នាក់ដែលត្រូវបានយល់ឃើញថាជាកម្មវត្ថុនៃ "បទចោទ" នៅពេលការស៊ើបអង្កេតបឋមបានចាប់ផ្តើមដំណើរការនៅក្នុងរឿងក្តីរបស់គាត់ ទោះបីជាពុំត្រូវបានចាប់ខ្លួនក៏ដោយ ជននេះបានដឹងជាផ្លូវការអំពីការស៊ើបអង្កេត និងបានចាប់ផ្តើមទទួលរងផលប៉ះពាល់ដោយសារវារួចទៅហើយ"[90]។ នៅក្នុងរឿងក្តីបច្ចុប្បន្ន [redacted] ត្រូវបានទទួលដំណឹងជាផ្លូវការដោយអាជ្ញាធរមានសមត្ថកិច្ច *ពោលគឺ* អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង អំពីការស៊ើបអង្កេតលើឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវ នៅពេលដែលគាត់បានទទួលការជូនដំណឹងនៅថ្ងៃទី ២៩ ខែ កុម្ភៈ។ ហេតុដូច្នេះ គាត់មានសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីត្រៀមការពារខ្លួនគាត់ ដូចមានចែងនៅក្នុងមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បន្ថែមលើសិទ្ធិទទួលបានការប្រព្រឹត្តមកលើស្មើគ្នានៅចំពោះមុខតុលាការ ដូចបានពិភាក្សាខាងលើនៅក្នុងន័យទូទៅ។

---

[88] *សូមមើល ឧ.* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Adolf ទល់នឹង អូទ្រីស* ពាក្យសុំលេខ 8269/78 សេចក្តីសម្រេច ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៨២ កថាខណ្ឌ ៣០។

[89] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Foti ទល់នឹង អ៊ីតាលី* ពាក្យសុំលេខ 7913/77 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២ កថាខណ្ឌ ៥១។

[90] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Kangasluoma ទល់នឹង ហ្វាំងឡង់* ពាក្យសុំលេខ 48339/99 ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៤ កថាខណ្ឌ ២៦។

26. ពាក់ព័ន្ធនឹងសិទ្ធិត្រៀមការពារខ្លួនវិញ [redacted] ត្រូវទទួលបានសិទ្ធិ "ត្រូវដឹង និងផ្តល់យោបល់លើសេចក្តីសង្កេតផ្សេងៗដែលបានដាក់ និងភស្តុតាងដែលបានផ្តល់ដោយភាគីផ្សេងទៀត"[91] នៅមុនពេលចេញសេចក្តីសម្រេចបញ្ជូនគាត់ទៅជំនុំជម្រះ ប្រសិនបើចុងក្រោយវានឹងដូច្នេះមែន។ ផ្ទុយនឹងការអះអាងរបស់មេធាវីការពារក្តី នេះពុំមានន័យថា [redacted] មានសិទ្ធិពិនិត្យសំណុំរឿងដោយស្វ័យប្រវត្តិនោះទេ ដោយសារតែច្បាប់សិទ្ធិមនុស្ស ដែលផ្តោតសំខាន់លើភាពយុត្តិធម៌ជារួមនៃកិច្ចដំណើរការនីតិវិធីនោះ ពុំបានកំណត់ពេលវេលាជាក់លាក់ថាតើត្រូវផ្តល់សិទ្ធិពិនិត្យសំណុំរឿងដល់បុគ្គលដែលរងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌនៅពេលណានោះឡើយ[92]។ ផ្ទុយមកវិញ ច្បាប់នេះតម្រូវឲ្យពិនិត្យមើលកិច្ចនានា ដែលកំពុងត្រូវបានអនុវត្តន៍ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដំណាក់កាលនេះ និងផលប៉ះពាល់ដែលអាចមាននៅទីបំផុត នៅក្នុងកិច្ចដំណើរការនីតិវិធីនៅពេលពិចារណាលើភាពចាំបាច់ដែលត្រូវផ្តល់សិទ្ធិឲ្យ [redacted] ពិនិត្យសំណុំរឿង[93]។ ត្រង់ចំណុច

---

[91] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Öcalan ទល់នឹង ទួគី* ពាក្យសុំលេខ 46221/99 សេចក្តីសម្រេច អង្គជំនុំជម្រះពេញអង្គ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ (សេចក្តីសម្រេច *Öcalan*) កថាខណ្ឌ ១៤៦។

[92] *សូមមើល ខ.* សេចក្តីសម្រេច *Öcalan* កថាខណ្ឌ ១៤០ ("តុលាការបានយល់ឃើញបន្ថែមទៀតថា ការគោរពលើសិទ្ធិរបស់ជនជាប់ចោទតម្រូវថា ការកម្រិតលើសិទ្ធិពិនិត្យមើលសំណុំរឿងដោយជនជាប់ចោទ ឬ មេធាវីការពារក្តី ពុំត្រូវរារាំងដល់ការផ្តល់ភស្តុតាងឲ្យជនជាប់ចោទនៅមុនពេលជំនុំជម្រះ និងការផ្តល់ឱកាសដល់ជនជាប់ចោទក្នុងការផ្តល់យោបល់លើភស្តុតាងតាមរយៈមេធាវីនៅក្នុងពេលធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នោះទេ")។ រឿងក្តី *X ទល់នឹង ស្វ៊ីស* ពាក្យសុំលេខ 4622/70 សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន គណៈកម្មាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៧២ កថាខណ្ឌ ២ (ដោយសារថា ជនជាប់ចោទមានឱកាសពិនិត្យមើលឡើងវិញលើរឿងក្តីនៅមុនពេលការជំនុំជម្រះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានយល់ឃើញថា ការពុំមានសិទ្ធិពិនិត្យមើលសំណុំរឿង *នៅមុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ* ពុំរំលោភលើសិទ្ធិត្រៀមរៀបចំការពារខ្លួននោះទេ)។ *សូមមើលផងដែរ* សេចក្តីណែនាំ 2012/13/EU នៃសភាអឺរ៉ុប និងក្រុមប្រឹក្សានៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីសិទ្ធិទទួលបានការជូនដំណឹងនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧ (តម្រូវឲ្យរដ្ឋសមាជិកបង្កើតនីតិវិធីសម្រាប់ "ផ្តល់សិទ្ធិ ដោយមិនគិតថ្លៃ ពិនិត្យមើលភស្តុតាងសម្ភារៈទាំងអស់ នៅក្នុងរយៈពេលគ្រប់គ្រាន់នៅមុនពេលជំនុំជម្រះ ដើម្បីអាចផ្តល់លទ្ធភាពឲ្យជនជាប់ចោទត្រៀមរៀបចំការការពារខ្លួនឲ្យមានប្រសិទ្ធភាព"។

[93] *សូមមើល* ក្រៅពីចំណុចយោងដែលត្រូវបានដកស្រង់នៅក្នុងលេខយោងជើងទំព័រខាងលើ៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Foucher ទល់នឹង បារាំង* ពាក្យសុំលេខ 22209/93 សេចក្តីសម្រេច ចុះថ្ងៃ ១៨ ខែ មីនា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៣២-៣៨ (នៅក្នុងករណីដែលតុលាការបានយល់ឃើញថា ការខកខានក្នុងការផ្តល់សិទ្ធិពិនិត្យមើលសំណុំរឿងដល់ជនជាប់ចោទ ដែលធ្វើជាតំណាងដោយខ្លួនឯង *នៅមុនពេលជំនុំជម្រះ* គឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការត្រៀមរៀបចំការការពារខ្លួន។ *សូមមើលផងដែរ* ជាទូទៅជាងនេះអំពីសិទ្ធិត្រៀមរៀបចំការការពារខ្លួន៖ សាលដីកាលើភាពអាចទុកចិត្តបាននៃភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម កថាខណ្ឌ ៣៣ (ដែលអង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា សិទ្ធិត្រៀមរៀបចំការការពារខ្លួនគឺត្រូវបានមើលឃើញនៅពេលរឿងក្តីដំណើរការទៅមុខ)។ សំណុំរឿង ០០២ (អ.ប.ជ ១០៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់

នេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានគូសបញ្ជាក់អំពី "សារសំខាន់នៃដំណាក់កាលស៊ើបអង្កេតសម្រាប់ការត្រៀមរៀបចំកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយហេតុថា ភស្តុតាងទទួលបាននៅក្នុងដំណាក់កាលនេះកំណត់ពីក្របខណ្ឌ ដែលបទល្មើសដូចបានចោទប្រកាន់នឹងត្រូវយកមកពិចារណានៅក្នុងពេលជំនុំជម្រះ"[94]។ តុលាការនេះបានគូសបញ្ជាក់ទៀតថា "ភាពយុត្តិធម៌នៃការជំនុំជម្រះទំនងទទួលរងប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយការខកខានពីដំបូងក្នុងការគោរពតាមបទប្បញ្ញត្តិស្តីពី [សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌]"[95]។ ដោយពិចារណាពីតួនាទីចម្បងនៃកិច្ចស៊ើបសួរនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក សិទ្ធិពិនិត្យសំណុំរឿង និងឱកាសចូលរួមនៅក្នុងកិច្ចស៊ើបសួរ ត្រូវតែផ្តល់ជូន [redacted] ឱ្យបានគ្រប់គ្រាន់នៅមុនពេលមានសេចក្តីសម្រេចថាតើត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងរូបគាត់ ដើម្បីឱ្យគាត់មានលទ្ធភាព*ពិតប្រាកដ*ក្នុងការពិនិត្យមើលឡើងវិញលើភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿង និងដើម្បីឱ្យគាត់ស្ថិតនៅក្នុងស្ថានភាពមួយដែលអាចស្នើសុំប្រមូលភស្តុតាងដោះបន្ទុក និងបង្ហាញអំពីជំហររបស់គាត់ឱ្យមានអត្ថន័យ។

27. យើងមិនអាចរង់ចាំការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការដាក់ការចោទប្រកាន់មកលើ [redacted] នោះទេ ហើយក៏មិនអាចរងចាំរហូតដល់កិច្ចស៊ើបសួរត្រូវបញ្ចប់នោះផងដែរ។ ទោះបីជាយ៉ាងនេះក្តី ដោយពិចារណាឃើញថា [redacted] ជាកម្មវត្ថុនៃការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ហើយការស៊ើបអង្កេតកំពុងត្រូវបានអនុវត្តអស់រយៈពេលជាងបួនឆ្នាំទៅហើយ ដោយមានការចូលរួមពីភាគីផ្សេងទៀតក្នុងកម្រិតមួយនោះ យើងយល់ឃើញថា [redacted] គួរត្រូវបានអនុញ្ញាតឱ្យអនុវត្តសិទ្ធិដែលផ្តល់ជូនដល់ "ជនត្រូវចោទ" អនុលោមតាមវិធាននៃផ្ទៃក្នុង ដើម្បីការពារសិទ្ធិរបស់គាត់ក្នុងការត្រៀមរៀបចំការពារខ្លួន និងដើម្បីធានានូវការគោរពតាមគោលការណ៍នៃសមភាពរវាងគូភាគីក្តី។ ការពន្យារពេលណាមួយបន្ថែមទៀតអាចបណ្តាលឱ្យ [redacted] មិនមានលទ្ធភាព

---

លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/15 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ២៣ (ក្នុងករណីដែលអង្គបុរេជំនុំជម្រះបានលើកឡើងថា "ការជជែកដេញដោលចំពោះមុខគឺអាចធ្វើទៅបាននៅក្នុងដំណាក់កាលនានានៃកិច្ចដំណើរការនីតិវិធី")។

[94] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Salduz ទល់នឹង ទួគី* ពាក្យសុំលេខ 36391/02 សេចក្តីសម្រេច អង្គជំនុំជម្រះពេញអង្គ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (សេចក្តីសម្រេច *Salduz*)។

[95] សេចក្តីសម្រេច *Salduz* អង្គជំនុំជម្រះពេញអង្គ កថាខណ្ឌ ៥០ (នៅក្នុងរឿងក្តីនេះ ម្ចាស់ដាក់ពាក្យសុំត្រូវបានបដិសេធសិទ្ធិមានមេធាវីខណៈនៅកន្លែងឃាត់ខ្លួន ប៉ុន្តែសំអាងហេតុអនុវត្ត*ដូចគ្នា*ចំពោះបញ្ហាចោទនៅក្នុងរឿងក្តីបច្ចុប្បន្ន)។

អនុវត្តសិទ្ធិទាំងនេះដោយមាន *ប្រសិទ្ធភាព* និងមានអត្ថន័យ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ដូចបានរំពឹងទុកនៅក្នុងវិធានផ្ទៃក្នុងទេ ដោយសារថា ភស្តុតាងស្ទើរតែទាំងអស់អាចត្រូវបានប្រមូលរួចរាល់អស់ហើយ ហើយសេចក្តីសម្រេចលើសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី អាចត្រូវបានធ្វើឡើង និងអនុវត្តរួចហើយ។ ដូច្នេះ គ្មានការការពារសិទ្ធិផ្នែកនីតិវិធីណាមួយនៅក្នុងដំណាក់កាលនេះអាចប៉ះប៉ូវចំពោះភាពខុសគ្នានៃការប្រព្រឹត្តិរវាងភាគីនោះទេ ហើយលទ្ធភាពរបស់ [redacted] ក្នុងការចង្អុលបង្ហាញលើភស្តុតាងដោះបន្ទុក និងបង្ហាញជំហររបស់គាត់ ដើម្បីឱ្យមានឥទ្ធិពលលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចទទួលរងផលប៉ះពាល់។ យើងកត់សម្គាល់ឃើញថា ករណីនេះបានបង្ហាញយ៉ាងច្បាស់ថាតើហេតុអ្វីបានជាការបកស្រាយលើសញ្ញាណនៃ "ជនត្រូវចោទ" ដូចបានធ្វើឡើងនៅក្នុងចំណុចខាងលើ អាចធានាយ៉ាងប្រសើរបំផុតឱ្យមានភាពស៊ីសង្វាក់គ្នានៃរបបគតិយុត្តិ ដូចបានរំពឹងទុកនៅក្នុងកម្រងច្បាប់ អ.វ.ត.ក គោលការណ៍ជាមូលដ្ឋានដូចបានកំណត់នៅក្នុងវិធានផ្ទៃក្នុង និងបទប្បញ្ញត្តិនៃមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

28. យោងតាមហេតុផលខាងលើ យើងយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានការភ័ន្តច្រឡំផ្នែកអង្គច្បាប់នៅពេលយល់ឃើញថា [redacted] ពុំមែនជា "ជនត្រូវចោទ" យោងតាមនិយមន័យនៃវិធានផ្ទៃក្នុង ដោយការយល់ឃើញនេះធ្វើឱ្យមានការច្រានចោលសំណើរបស់គាត់ស្នើសុំសិទ្ធិពិនិត្យសំណុំរឿង និងចូលរួមនៅក្នុងកិច្ចស៊ើបសួរ។ ដោយសារបញ្ហានេះហើយ តាមទស្សនៈរបស់យើង សេចក្តីសម្រេចដែលត្រូវបានជំទាស់គួរត្រូវបានកែប្រែ ដោយសារវាបានបដិសេធលើសំណើរបស់ [redacted] ស្នើសុំការចូលរួមនៅក្នុងកិច្ចស៊ើបសួរ។ យើងក៏យល់ឃើញផងដែរថា ជាគោលការណ៍ មេធាវីរបស់ [redacted] គួរត្រូវបានផ្តល់សិទ្ធិពិនិត្យសំណុំរឿង។ ទោះបីជាយ៉ាងនេះក្តី យើងពុំមានលទ្ធភាពយល់ព្រមតាមសំណើសុំសិទ្ធិពិនិត្យសំណុំរឿង និងបង្គាប់ឱ្យផ្តល់សិទ្ធិពេញលេញ និងដោយគ្មានកំណត់ដល់មេធាវីរបស់ [redacted] ក្នុងការពិនិត្យសំណុំរឿង បាននោះទេ ដោយសារយើងមិនអាចវាយតម្លៃលើផលប៉ះពាល់នៃការសម្រេចបែបនេះដែលអាចកើតមានលើកិច្ចស៊ើបសួរដែលកំពុងបន្តធ្វើឡើងនេះទេ។

29. ត្រង់ចំណុចនេះ យើងទទួលស្គាល់ថា វាអាចមានហេតុផលស្របច្បាប់ក្នុងការពន្យារពេលក្នុងការផ្តល់សិទ្ធិឱ្យពិនិត្យសំណុំរឿង កំហិតព័ត៌មានមួយចំនួនចំពោះមេធាវី និងកំហិតការបញ្ជូនព័ត៌មានជូនទៅ [redacted] នៅក្នុងកិច្ចនីតិវិធីក្នុងដំណាក់កាលនេះ។ ដោយសារទាំងកម្រងច្បាប់ អ.វ.ត.ក

និងច្បាប់កម្ពុជា ពុំបានដោះស្រាយលើបញ្ហានេះ យើងកត់សម្គាល់ឃើញថា វិធានផ្នែកនីតិវិធីដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ[96] ដែលមានលក្ខណៈស្រដៀងនឹងប្រព័ន្ធច្បាប់ក្នុងស្រុក អនុញ្ញាតឲ្យដាក់កំហិតលើព័ត៌មានដែលត្រូវផ្ដល់ជូនជនជាប់ចោទ ដើម្បីការពារផលប្រយោជន៍នានា ដូចជា សុចរិតភាពនៃកិច្ចស៊ើបសួរ សន្តិសុខរបស់ជនរងគ្រោះ និងសាក្សី ព្រមទាំងសន្តិសុខជាតិ ឬអន្តរជាតិ[97]។ ទោះបីជានៅតាមបណ្ដាសាលាក្ដីអន្តរជាតិ និងសាលាក្ដីអន្តរជាតូបនីយកម្មផ្សេងទៀត ពុំមានការស៊ើបសួររបស់តុលាការ ឬគ្មាន "សំណុំរឿងជាផ្លូវការ" ក៏ដោយ[98] ក៏វិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់សាលាក្ដីទាំងអស់នេះ បានផ្ដល់លទ្ធភាពឲ្យកំហិតលើកាតព្វកិច្ចរបស់ស្ថាប័នអយ្យការក្នុងការលាតត្រដាងព័ត៌មាន ដែលដូច្នេះ រក្សាទុកភស្តុតាងមិនឲ្យជនជាប់ចោទដឹងក្នុងរយៈពេលមួយក្រោមការពិនិត្យតាមដានរបស់តុលាការ ដើម្បីការពារផលប្រយោជន៍ដូចដែលបានលើកឡើងខាងលើ[99]។ នៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកដែលអនុវត្តតាមប្រព័ន្ធច្បាប់

---

[96] *សូមមើល* មាត្រា ២៣ថ្មី (១) នៃច្បាប់ អ.វ.ត.ក (ដែលចែងត្រង់ផ្នែកពាក់ព័ន្ធថា "ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ...សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ")។

[97] *សូមមើល ឧ.* តុលាការពិសេសសម្រាប់ប្រទេសលីបង់ *នៅក្នុងរឿងក្ដី El Sayed* សំណុំរឿង CH/PTJ/2010/005 ដីកាសម្រេចពាក់ព័ន្ធនឹងយុត្តាធិការនៃសាលាក្ដីដើម្បីសម្រេចលើពាក្យសុំរបស់ *El Sayed* ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១០ និងថាតើលោក *El Sayed* មានឋានៈនៅចំពោះមុខសាលាក្ដីដែរឬទេ ចៅក្រមអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៥៣ ("ពាក់ព័ន្ធនឹងបញ្ហានៃការអនុវត្តសិទ្ធិពិនិត្យមើលសំណុំរឿងព្រហ្មទណ្ឌ វាកើតចេញពីច្បាប់ និងយុត្តិសាស្ត្រ ទាំងអន្តរជាតិ និងជាតិ ដែលលើកឡើងថា សិទ្ធិនេះពុំមែនជាសិទ្ធិដាច់ខាត។ ជាការពិត សិទ្ធិនេះអាចស្ថិតនៅក្រោមលក្ខខណ្ឌកម្រិត។ ករណីនេះកើតឡើងជាពិសេសចេញពីអង្គហេតុថា ការផ្ដល់ឯកសារអាចធ្វើឲ្យប៉ះពាល់ដល់ការស៊ើបអង្កេតដែលកំពុងធ្វើឡើង ឬការស៊ើបអង្កេតនាពេលអនាគត អាចធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ជាមូលដ្ឋាន ដូចជា សុខមាលភាពផ្លូវកាយរបស់បុគ្គលដែលពាក់ព័ន្ធនឹងឯកសារទាំងនេះ ឬ ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ និងអន្តរជាតិ។ លក្ខខណ្ឌកម្រិតទាំងនេះក៏អាចកើតចេញពីការលំបាកនានាដែលកើតមានមកជាមួយនឹងដំណើរការស៊ើបអង្កេតលើភេរវជន")។

[98] *សូមមើល* Hakan Friman សេចក្ដីផ្ដើមនៃច្បាប់ និងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ Cambridge University Press ឆ្នាំ ២០១០ ទំព័រ ៤៦២-៤៦៣ ("នីតិវិធីនៃសាលាក្ដី ICTY និងសាលាក្ដី ICTR មានលក្ខណៈជានីតិវិធីចំពោះមុខ ហើយការលាតត្រដាងណាមួយត្រូវបានបញ្ញត្តិតាមគោលការណ៍នេះ") *និង* ទំព័រ ៤៦៤ ("នៅតុលាការ ICC ការលាតត្រដាង [ក៏] កើតឡើងរវាងភាគី ហើយ តាំងពីមុនមក យើងឃើញមាន "សំណុំឯកសារ" រួមបញ្ចូលអ្វីៗទាំងអស់")។

[99] *សូមមើល* វិធាន ៦៦(គ) ៦៨(iv) ៦៩(ក) ៧០(ខ) និង៧៥(ក) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់សាលាក្ដី ICTY។ វិធាន ៦៦(គ) ៦៨(ឃ) ៦៩(ក) ៧០(ខ) និង៧៥(ក) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់សាលាក្ដី ICTR។ វិធាន ៨១(២) ៨១(៣) ៨១(៤) និង១៣៣(ក) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់សាលាក្ដី ICC។ វិធាន ៣៩(ii) ៦៦(ខ) ៦៩(ក) ៧០(ខ)

ខំមិនឡូ (common law)[100] និងស៊ីវិលឡូ (civil law)[101] ក៏អនុវត្តដូចច្នេះដែរ។ គួរកត់សម្គាល់ថា អាជ្ញាស៊ើបអង្កេតនៅក្នុងប្រព័ន្ធស៊ើបអង្កេតដឹកនាំដោយចៅក្រម ត្រូវបានផ្ដល់ឆន្ទានុសិទ្ធិច្រើនក្នុង

---

និង ៧៥(ក) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន។ វិធាន ៥៥(គ) ១១៥(ក) ១១៦(ក) ១១៧(ក) និង ១១៨(ក) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងតុលាការពិសេសសម្រាប់ប្រទេសលីបង់។

[100] *សូមមើល ខ.* ***នៅក្នុងប្រទេសកាណាដា៖*** រឿងក្ដី *R. ទល់នឹង Stinchcombe* [ឆ្នាំ ១៩៩១] ៣ S.C.R ៣២៦ នៅត្រង់ទំព័រ ៣៤៩ (ដែលលើកឡើងថា ស្ថាប័នអយ្យការមានអំណាចឆន្ទានុសិទ្ធិ ប៉ុន្តែ ត្រូវស្ថិតនៅក្រោមការពិនិត្យឡើងវិញតាមផ្លូវតុលាការ អាចបដិសេធលើការលាតត្រដាងព័ត៌មាន ឬ ពន្យារពេលក្នុងការលាតត្រដាងព័ត៌មាន ពោលគឺ អាចការពារអត្តសញ្ញាណនៃអ្នកផ្ដល់ព័ត៌មាន និងសន្តិសុខរបស់សាក្សី) **នៅក្នុងប្រទេសអង់គ្លេស និងប្រទេសវែល៖** ផ្នែក ១៤ ដល់ ១៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ និងការស៊ើបអង្កេតឆ្នាំ ១៩៩៦ (ដែលចែងថា លក្ខខណ្ឌនៃការលាតត្រដាងដោយមិនលម្អៀងត្រូវអនុវត្តតាម លើកលែងតែករណីសម្ភារៈនោះមានលក្ខណៈរសើប ដែលនៅក្នុងករណីបែបនេះ សំណើសុំអំពីអភ័យឯកសិទ្ធិនៃផលប្រយោជន៍សាធារណៈអាចធ្វើឡើងនៅចំពោះមុខតុលាការ) និង**នៅក្នុងរដ្ឋវិចតូរីយ៉ា (ប្រទេសអូស្ត្រាលី)៖** រឿងក្ដី *Sankey ទល់នឹង Whitlam* (ឆ្នាំ ១៩៧៨) ១៤២ CRL ១ Gibbs ACJ ត្រង់ទំព័រ ៣៨-៣៩ (ដោយយោងលើបទដ្ឋានស្រដៀងគ្នាជាបទដ្ឋានដែលត្រូវបានអនុវត្តនៅក្នុងប្រទេសអង់គ្លេស)។

[101] **នៅក្នុងប្រទេសបារាំង** នៅមុនពេលបញ្ជូនសំណុំរឿងទៅកាន់កូនក្ដីរបស់ខ្លួន មេធាវីការពារក្ដីត្រូវជូនដំណឹងដល់ចៅក្រមស៊ើបអង្កេត ដែលអាចហាមឃាត់មិនឱ្យបញ្ជូនសំណុំរឿងដោយផ្អែកលើហេតុផលថាមានហានិភ័យនៃការដាក់សម្ពាធលើសាក្សី ជនរងគ្រោះ ជនផ្សេងទៀតដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមត្រួតពិនិត្យតាមផ្លូវតុលាការ អ្នកស៊ើបអង្កេត អ្នកជំនាញ ឬ ជនណាដែលបានចូលរួមចំណែកនៅក្នុងការស៊ើបអង្កេត (*សូមមើល* មាត្រា ១១៤(៥) នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង)។ **នៅក្នុងប្រទេសអាល្លឺម៉ង់** នៅមុនពេលចេញសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរដោយរដ្ឋអាជ្ញា សិទ្ធិពិនិត្យមើលសំណុំរឿងអាចត្រូវបានបដិសេធមិនផ្ដល់ឱ្យមេធាវីការពារក្ដីនៅក្នុងករណីដែលសិទ្ធិនេះ "អាចបង្កគ្រោះថ្នាក់ដល់គោលបំណងនៃការស៊ើបអង្កេត" (*សូមមើល* ផ្នែក ១៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់)។ សិទ្ធិពិនិត្យមើលសំណុំរឿងអាចត្រូវបានរិតត្បិតនៅក្នុងពេលណាមួយ ហើយត្រូវផ្ដល់ជូនមកវិញ យ៉ាងយូរបំផុត នៅពេលបញ្ចប់ការស៊ើបសួរ (*សូមមើល* ផ្នែក ១៤៧(៦) នៃក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់)។ នៅក្នុងករណីណាក៏ដោយ មេធាវីការពារក្ដី មិនថានៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីណាមួយនោះទេ ពុំអាចត្រូវបានគេបដិសេធមិនឱ្យពិនិត្យមើលកំណត់ហេតុពាក់ព័ន្ធនឹងការដាក់ការត្រួតពិនិត្យលើជនជាប់ចោទ ឬពាក់ព័ន្ធនឹងកិច្ចស៊ើបសួរណាមួយ ដែលជនជាប់ចោទត្រូវបានទទួលស្គាល់ ឬ គួរតែត្រូវបានទទួលស្គាល់ឱ្យចូលរួម ហើយមេធាវីការពារក្ដីក៏មិនអាចត្រូវបានគេបដិសេធមិនឱ្យពិនិត្យមើលមតិយោបល់របស់អ្នកជំនាញផងដែរ (*សូមមើល* ផ្នែក ១៤៧(៣)នៃក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់)។ **នៅក្នុងប្រទេសកូសូវ៉ូ** មាត្រា ២១៣(៧) និង(៨) ចែងនូវការដាក់កម្រិតលើសិទ្ធិពិនិត្យមើលសំណុំរឿង៖ "៧. ព័ត៌មានអាចត្រូវបានកោសលុប ឬ គូសចោលដោយខ្សែបន្ទាត់ក្រាសពណ៌ខ្មៅដើម្បីលុបព័ត៌មានជាក់លាក់មួយចំនួនដោយរដ្ឋអាជ្ញានៅពេលថតចម្លងឯកសារដែលមានព័ត៌មានរសើប។ ជនជាប់ចោទអាចជំទាស់នឹងការកោសលុបនេះទៅចៅក្រមអង្គបុរេជំនុំជម្រះ ចៅក្រមជំនុំជម្រះទោល ឬចៅក្រមប្រធានជំនុំជម្រះនៅក្នុងរយៈពេលបីថ្ងៃក្រោយពីបានទទួលឯកសារច្បាប់ថតចម្លងដែលមានការកោសលុប។ រដ្ឋអាជ្ញាត្រូវផ្ដល់ឱកាសឱ្យពន្យល់មូលដ្ឋានផ្លូវច្បាប់នៃការកោសលុបនេះដោយពុំត្រូវលាតត្រដាងព័ត៌មានរសើបឡើយ។ ចៅក្រមត្រូវពិនិត្យមើលឡើងវិញចំពោះព័ត៌មានដែលត្រូវបានកោសលុបនេះ ហើយត្រូវ

ការកំហិតលើសិទ្ធិពិនិត្យ "សំណុំរឿង" នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[102] ដោយសារថា ការផ្តល់សិទ្ធិពិនិត្យសំណុំរឿងនៅក្នុងខណៈពេលដែលការស៊ើបអង្កេតកំពុងនៅបន្តធ្វើឡើង និងនៅមុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ វានឹងធ្វើឱ្យហានិភ័យលើសុចរិតភាពនៃការស៊ើបអង្កេតនឹងកាន់តែខ្ពស់ ហើយការដាក់កំហិតណាមួយលើសិទ្ធិពិនិត្យសំណុំរឿងនៅក្នុងដំណាក់កាលនេះ វាក៏អាចនឹងជួសជុលយ៉ាងងាយស្រួលតាមរយៈការធានាលើសិទ្ធិផ្នែកនីតិវិធី។ តាមទស្សនៈវិស័យផ្នែកសិទ្ធិមនុស្ស ការដាក់កំហិតលើការធានាលើសិទ្ធិផ្នែកនីតិវិធី ដូចជាសិទ្ធិពិនិត្យសំណុំរឿងអាចទទួលយកបាន ដរាបណា (i) ការដាក់កំហិតនេះធ្វើឡើងដើម្បីបំរើផលប្រយោជន៍ស្របច្បាប់ ហើយ (ii) បើពិនិត្យមើលលើកិច្ចដំណើរការនីតិវិធីទាំងមូល ជនជាប់ចោទមិនត្រូវបានដកហូតចេញនូវសវនាការដ៏យុត្តិធម៌ទេ[103]។ ត្រង់ចំណុចនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានលើកឡើងថា៖

> 78. ទោះបីជាយ៉ាងណាក៏ដោយ សិទ្ធិក្នុងការលាតត្រដាងភស្តុតាងពាក់ព័ន្ធពុំមែនជាសិទ្ធិដាច់ខាតនោះទេ។ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ អាចមានផលប្រយោជន៍ប្រកួតប្រជែងគ្នាច្រើន ដូចជា សន្តិសុខជាតិ ឬ ភាពចាំបាច់ក្នុងការការពារសាក្សីដែលប្រឈមនឹងការសងសឹក ឬភាពចាំបាច់ក្នុងការរក្សាការសម្ងាត់លើវិធីស៊ើបអង្កេតរបស់នគរបាលចំពោះឧក្រិដ្ឋកម្ម ដែលចំណុចទាំងនេះត្រូវតែថ្លឹងថ្លែងជាមួយសិទ្ធិរបស់ជនជាប់ចោទ។ នៅក្នុងករណីខ្លះ ចាំបាច់ត្រូវរក្សាទុកភស្តុតាងមួយចំនួនមិនឱ្យជនជាប់ចោទដឹង ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់បុគ្គលម្នាក់ទៀត ឬដើម្បីធានាផលប្រយោជន៍សាធារណៈ។ ទោះបីជាយ៉ាងនេះក្តី មានតែវិធានការដែលកំហិតសិទ្ធិរបស់ជនជាប់ចោទ ដែលមានភាពចាំបាច់បំផុតតែប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឱ្យដាក់កំហិតទៅបានអនុលោមតាមមាត្រា ៦ § ១។ លើសពីនេះទៀត ដើម្បីធានាថា ជនជាប់ចោទទទួលបានការជំនុំជម្រះមួយដ៏យុត្តិធម៌ ការលំបាកណាមួយដែលកើតមានឡើងចំពោះមេធាវីការពារក្តីដោយសារតែការដាក់

---

សម្រេចក្នុងរយៈពេលបីថ្ងៃថាតើការកោសលុបនេះមានយុត្តិកម្មតាមផ្លូវច្បាប់ដែរឬទេ។ ៨. បទប្បញ្ញត្តិនៃមាត្រាបច្ចុប្បន្ននេះត្រូវគោរពតាមវិធានការការពារភាគី និងសាក្សីដែលទទួលរងព្យសនកម្ម និងភាពឯកជនរបស់ពួកគេ និងការពារព័ត៌មានសម្ងាត់ដូចបានកំណត់ដោយច្បាប់"។

[102] *សូមមើល* ចំណុចយោងដូចបានដកស្រង់នៅក្នុងលេខយោងជើងទំព័រខាងលើ។

[103] *សូមមើល ឧ.* ស្តីពីការដាក់កំហិតលើសិទ្ធិរបស់មេធាវី សេចក្តីសម្រេច *Salduz* កថាខណ្ឌ ៥២។

កំហិតលើសិទ្ធិរបស់ពួកគេ ត្រូវតែមានការដោះស្រាយឱ្យបានគ្រប់គ្រាន់ អនុលោមតាមនីតិវិធីដែលអនុវត្តដោយអាជ្ញាធរស៊ើបអង្កេត[104]។

ហេតុដូច្នេះ យើងយល់ឃើញថា ចំពោះសំណើសុំសិទ្ធិពិនិត្យមើលសំណុំរឿង ករណីនេះគួរតែត្រូវបង្វិលត្រឡប់ជូនទៅសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីឱ្យគាត់ធ្វើការសម្រេចទៅតាមច្បាប់។

**រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤**

Rowan DOWNING Chang-ho CHUNG

[104] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Leas ទល់នឹង អេស្តូនី* ពាក្យសុំលេខ 59577/08 សេចក្តីសម្រេច កថាខណ្ឌ ៧៨ (ចំណុចយោងត្រូវបានលុបចោល)។